ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Prakas MOH

ក្រសួងសុខាភិបាល
លេខ ០៣៤ ឋ.ឃ.ស.ល / ស.ល

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០០៩

# ប្រកាស
## ស្តីពី
## ការកែសម្រួលបែបបទ និងល័ក្ខខ័ណ្ឌបច្ចេកទេស ក្នុងការសុំបើកឬបិទ សុំកែប្រែទ្រង់ទ្រាយ ឬប្តូរទីតាំង នៃសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ នស/រក/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ

-បានឃើញ អនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញ អនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីបែបបទនិងល័ក្ខខ័ណ្ឌនៃការអនុញ្ញាតឱ្យជនបរទេសជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី២១-១០-១៩៩៤

-និងយោង តាមការចាំបាច់របស់ក្រសួងសុខាភិបាល។

## ស ម្រេ ច

ប្រការ ១.-

ខ្លឹមសារប្រកាសលេខ ០៦១/០១ អបស/មព ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៣ របស់ក្រសួងសុខាភិបាល ត្រូវបានកែសម្រួលដូចខាងក្រោម។



9

ការិយាល័យរដ្ឋមន្ត្រីក្រសួងសុខាភិបាល ,លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៤២៦ ០៣៤ / ៤២៦ ៨៤១ ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៨៧៣

ប្រការ ២.-

ការបើក ការបិទ ការកែទ្រង់ទ្រាយ ការប្តូរទីតាំង ការបន្តសុពលភាព បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ បន្ទប់ថែទាំជំងឺ បន្ទប់ព្យាបាលដោយចលនា បន្ទប់ពិគ្រោះព្យាបាលជំងឺ បន្ទប់ពិគ្រោះព្យាបាលជំងឺមាត់-ធ្មេញ បន្ទប់ពិគ្រោះព្យាបាលជំងឺភ្នែក បន្ទប់ពិគ្រោះព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់ក បន្ទប់ពិគ្រោះព្យាបាលជំងឺសើស្បែក និងបន្ទប់ពិគ្រោះព្យាបាលជំងឺផ្លូវចិត្ត អាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតពីមន្ទីរសុខាភិបាលរាជធានី-ខេត្ត។

ប្រការ ៣.-

ការបើក ការបិទ ការកែទ្រង់ទ្រាយ ការប្តូរទីតាំង ការផ្លាស់ប្តូរអ្នកគ្រប់គ្រង ការបន្តសុពលភាព មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល មន្ទីរសម្ភព-រោគស្ត្រី មន្ទីរពិសោធន៍វេជ្ជសាស្ត្រ មន្ទីរព្យាបាលមាត់-ធ្មេញ មន្ទីរព្យាបាលជំងឺភ្នែក មន្ទីរព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់ក មន្ទីរព្យាបាលជំងឺសើស្បែក មន្ទីរព្យាបាលជំងឺផ្លូវចិត្ត មន្ទីរព្យាបាលជំងឺកុមារ មជ្ឈមណ្ឌលកែសម្ផស្ស និងការិយាល័យតំណាង ឬការិយាល័យទំនាក់ទំនងសេវាសុខភាព អាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល។

ប្រការ ៤.-

ក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាលរាជធានី-ខេត្ត មានសិទ្ធិព្រមាន ឬផ្អាក ឬបញ្ឈប់ការបើកសេវាបន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ បន្ទប់ថែទាំជំងឺ បន្ទប់ព្យាបាលដោយចលនា បន្ទប់ពិគ្រោះព្យាបាលជំងឺ បន្ទប់ពិគ្រោះព្យាបាលជំងឺមាត់-ធ្មេញ បន្ទប់ពិគ្រោះព្យាបាលជំងឺភ្នែក បន្ទប់ពិគ្រោះព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់ក បន្ទប់ពិគ្រោះព្យាបាលជំងឺសើស្បែក និងបន្ទប់ពិគ្រោះព្យាបាលជំងឺផ្លូវចិត្ត ក្នុងករណីពិនិត្យឃើញថា :

១-សាមីជនរៀបចំសេវាមិនសមស្របតាមល័ក្ខខ័ណ្ឌកំណត់របស់ក្រសួងសុខាភិបាល

២-សាមីជនមិនគោរពតាមកិច្ចសន្យា និងការណែនាំរបស់ក្រសួងសុខាភិបាល

៣-សាមីជនមានទោសពីបទល្មើសព្រហ្មទណ្ឌកម្រិតមជ្ឈិម ឬឧក្រិដ្ឋ។

ប្រការ ៥.-

ក្រសួងសុខាភិបាលមានសិទ្ធិព្រមាន ឬផ្អាក ឬបញ្ឈប់ការបើកសេវា មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល មន្ទីរសម្ភព-រោគស្ត្រី មន្ទីរពិសោធន៍វេជ្ជសាស្ត្រ មន្ទីរព្យាបាលមាត់-ធ្មេញ មន្ទីរព្យាបាលជំងឺភ្នែក មន្ទីរព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់ក មន្ទីរព្យាបាលជំងឺសើស្បែក មន្ទីរព្យាបាលជំងឺផ្លូវចិត្ត មន្ទីរព្យាបាលជំងឺកុមារ មជ្ឈមណ្ឌលកែសម្ផស្ស និងការិយាល័យតំណាង ឬការិយាល័យទំនាក់ទំនងសេវាសុខភាព ក្នុងករណីពិនិត្យឃើញថា :

១-សាមីជនរៀបចំសេវាមិនសមស្របតាមល័ក្ខខ័ណ្ឌកំណត់របស់ក្រសួងសុខាភិបាល



10

២-សាមីជនមិនគោរពតាមកិច្ចសន្យា និងការណែនាំរបស់ក្រសួងសុខាភិបាល

៣-សាមីជនមានទោសពីបទល្មើសព្រហ្មទណ្ឌកម្រិតមជ្ឈិម ឬឧក្រិដ្ឋ។

ប្រការ ៦.-

សំណុំលិខិតសុំបើក បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ បន្ទប់ថែទាំជំងឺ បន្ទប់ព្យាបាលដោយចលនា បន្ទប់ពិគ្រោះព្យាបាលជំងឺ បន្ទប់ពិគ្រោះព្យាបាលជំងឺមាត់-ធ្មេញ បន្ទប់ពិគ្រោះព្យាបាលជំងឺភ្នែក បន្ទប់ពិគ្រោះព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់ក បន្ទប់ពិគ្រោះព្យាបាលជំងឺសើស្បែក និងបន្ទប់ពិគ្រោះព្យាបាលជំងឺផ្លូវចិត្ត មាន :

១-ពាក្យសុំបើកសេវា "មានគំរូ" ០១ច្បាប់

២-ជីវប្រវត្តិសង្ខេបរបស់សាមីជន "មានគំរូ" ០១ច្បាប់

៣-កិច្ចសន្យារបស់សាមីជន "មានគំរូ" ០១ច្បាប់

៤-វិញ្ញាបនបត្រសុខភាព ចេញដោយក្រសួងសុខាភិបាល ឬមន្ទីរពេទ្យរដ្ឋ ០១ច្បាប់

៥-គំនូសបំព្រួញទីតាំងដោយមានបញ្ជាក់ពីឃុំ/សង្កាត់ ០១ច្បាប់

៦-សញ្ញាប័ត្រដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ឬក្រសួងអប់រំយុវជននិងកីឡា ឬគណៈកម្មាធិការពិនិត្យវាយតម្លៃកម្រិតសញ្ញាប័ត្រ និងលិខិតបញ្ជាក់ការសិក្សា (ថតចម្លងបញ្ជាក់ពីសាលារាជធានី-ខេត្ត) ០១ច្បាប់

៧-លិខិតបញ្ជាក់ថាបានចុះឈ្មោះក្នុងគណៈវិជ្ជាជីវៈ ០១ច្បាប់

៨-រូបថតសាមីជន (បច្ចុប្បន្ន) ៤ X ៦ ស.ម ចំនួន ០៧ សន្លឹក

ប្រការ ៧.-

សំណុំលិខិតសុំប្តូរទីតាំង បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ បន្ទប់ថែទាំជំងឺ បន្ទប់ព្យាបាលដោយចលនា បន្ទប់ពិគ្រោះព្យាបាលជំងឺ បន្ទប់ពិគ្រោះព្យាបាលជំងឺមាត់-ធ្មេញ បន្ទប់ពិគ្រោះព្យាបាលជំងឺភ្នែក បន្ទប់ពិគ្រោះព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់ក បន្ទប់ពិគ្រោះព្យាបាលជំងឺសើស្បែក និងបន្ទប់ពិគ្រោះព្យាបាលជំងឺផ្លូវចិត្ត មាន :

១-ពាក្យសុំប្តូរទីតាំង "មានគំរូ" ០១ច្បាប់

២-ជីវប្រវត្តិសង្ខេបរបស់សាមីជន "មានគំរូ" ០១ច្បាប់

៣-កិច្ចសន្យារបស់សាមីជន "មានគំរូ" ០១ច្បាប់

៤-វិញ្ញាបនបត្រសុខភាព ចេញដោយក្រសួងសុខាភិបាល ឬមន្ទីរពេទ្យរដ្ឋ ០១ច្បាប់

៥-គំនូសបំព្រួញទីតាំងដោយមានបញ្ជាក់ពីឃុំ/សង្កាត់ ០១ច្បាប់

៦-សញ្ញាប័ត្រដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ឬក្រសួងអប់រំយុវជននិងកីឡា ឬគណៈកម្មាធិការពិនិត្យវាយតម្លៃកម្រិតសញ្ញាប័ត្រ និងលិខិតបញ្ជាក់ការសិក្សា (ថតចម្លងបញ្ជាក់ពីសាលារាជធានី-ខេត្ត) ០១ច្បាប់

៧-លិខិតបញ្ជាក់ថាបានចុះឈ្មោះក្នុងគណៈវិជ្ជាជីវៈ 	០១ច្បាប់

៨-រូបថតសាមីជន (បច្ចុប្បន្ន) ៤ X ៦.ស.ម ចំនួន 	០៧ សន្លឹក

ប្រការ ៨.-

សំណុំលិខិតសុំបើក មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល មន្ទីរសម្ភព-រោគស្ត្រី មន្ទីរពិសោធន៍វេជ្ជសាស្ត្រ មន្ទីរព្យាបាលមាត់-ធ្មេញ មន្ទីរព្យាបាលជំងឺភ្នែក មន្ទីរព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់ក មន្ទីរព្យាបាលជំងឺសើស្បែក មន្ទីរព្យាបាលជំងឺផ្លូវចិត្ត មន្ទីរព្យាបាលជំងឺកុមារ មជ្ឈមណ្ឌលកែសម្ផស្ស និងការិយាល័យតំណាង ឬការិយាល័យទំនាក់ទំនងសេវាសុខភាព មាន ៖

១-ពាក្យសុំបើកសេវា "មានគំរូ" 	០១ច្បាប់

២-ជីវប្រវត្តិសង្ខេបរបស់សាមីជន "មានគំរូ" 	០១ច្បាប់

៣-កិច្ចសន្យារបស់សាមីជន "មានគំរូ" 	០១ច្បាប់

៤-វិញ្ញាបនបត្រសុខភាព ចេញដោយក្រសួងសុខាភិបាល ឬមន្ទីរពេទ្យរដ្ឋ 	០១ច្បាប់

៥-គំនូសបំព្រួញទីតាំង ដោយមានបញ្ជាក់ពីឃុំ/សង្កាត់ 	០១ច្បាប់

៦-សញ្ញាប័ត្រដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ឬក្រសួងអប់រំយុវជននិងកីឡា ឬគណៈកម្មាធិការពិនិត្យវាយតម្លៃកម្រិតសញ្ញាប័ត្រ និងលិខិតបញ្ជាក់ការសិក្សា (ថតចម្លងបញ្ជាក់ពីសាលារាជធានី-ខេត្ត) 	០១ច្បាប់

៧-លិខិតបញ្ជាក់ថាបានចុះឈ្មោះក្នុងបញ្ជីគណៈវិជ្ជាជីវៈ 	០១ច្បាប់

៨-លិខិតថ្កោលទោស ចំពោះអ្នកមិនបម្រើការងាររដ្ឋ 	០១ច្បាប់

៩-រូបថតសាមីជន (បច្ចុប្បន្ន) ៤ X ៦ ស.ម ចំនួន 	០៧ សន្លឹក

១០-សាមីជនត្រូវបំពេញសំណុំលិខិតខាងលើ ហើយបញ្ជូនមកនាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត ។

ប្រការ ៩.-

សំណុំលិខិតប្តូរទីតាំង មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល មន្ទីរសម្ភព-រោគស្ត្រី មន្ទីរពិសោធន៍វេជ្ជសាស្ត្រ មន្ទីរព្យាបាលមាត់-ធ្មេញ មន្ទីរព្យាបាលជំងឺភ្នែក មន្ទីរព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់ក មន្ទីរព្យាបាលជំងឺសើស្បែក មន្ទីរព្យាបាលជំងឺផ្លូវចិត្ត មន្ទីរព្យាបាលជំងឺកុមារ មជ្ឈមណ្ឌលកែសម្ផស្ស និងការិយាល័យតំណាង ឬការិយាល័យទំនាក់ទំនងសេវាសុខភាព មាន ៖

១-ពាក្យសុំប្តូរទីតាំងសេវា "មានគំរូ" 	០១ច្បាប់

២-ជីវប្រវត្តិសង្ខេបរបស់សាមីជន "មានគំរូ" 	០១ច្បាប់

៣-កិច្ចសន្យារបស់សាមីជន "មានគំរូ" 	០១ច្បាប់

៤-វិញ្ញាបនបត្រសុខភាព ចេញដោយក្រសួងសុខាភិបាល ឬមន្ទីរពេទ្យរដ្ឋ ០១ច្បាប់

៥-គំនូសបំព្រួញទីតាំង ដោយមានបញ្ជាក់ពីឃុំ/សង្កាត់ ០១ច្បាប់

៦-សញ្ញាប័ត្រដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ឬក្រសួងអប់រំយុវជននិងកីឡា ឬគណៈកម្មាធិការពិនិត្យវាយតម្លៃកម្រិតសញ្ញាប័ត្រ និងលិខិតបញ្ជាក់ការសិក្សា (ថតចម្លងបញ្ជាក់ពីសាលារាជធានី-ខេត្ត) ០១ច្បាប់

៧-លិខិតបញ្ជាក់ថាបានចុះឈ្មោះក្នុងបញ្ជីគណៈវិជ្ជាជីវៈ ០១ច្បាប់

៨-លិខិតថ្កោលទោស ចំពោះអ្នកមិនបម្រើការងាររដ្ឋ ០១ច្បាប់

៩- រូបថតសាមីជន (បច្ចុប្បន្ន) ៤ X ៦ ស.ម ចំនួន ០៧ សន្លឹក

១០-សាមីជនត្រូវបំពេញសំណុំលិខិតខាងលើ ហើយបញ្ជូនមកនាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត។

ប្រការ ១០.-

សំណុំលិខិតផ្ទេរអ្នកគ្រប់គ្រង (ផ្ទេរមូលនិធិ) មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល មន្ទីរសម្ភព មន្ទីរពិសោធន៍វេជ្ជសាស្ត្រ មន្ទីរព្យាបាលមាត់-ធ្មេញ មន្ទីរព្យាបាលជំងឺភ្នែក មន្ទីរព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់ក មន្ទីរព្យាបាលជំងឺស្បែក មន្ទីរព្យាបាលជំងឺផ្លូវចិត្ត មន្ទីរព្យាបាលជំងឺកុមារ មជ្ឈមណ្ឌលកែសម្ផស្ស និងការិយាល័យតំណាង ឬការិយាល័យទំនាក់ទំនងសេវាសុខភាព មាន ៖

១-ពាក្យសុំផ្ទេរអ្នកគ្រប់គ្រង "មានតែំរូ" ០១ច្បាប់

២-កិច្ចព្រមព្រៀងផ្ទេរសិទ្ធិរវាងអ្នកគ្រប់គ្រងចាស់ផ្លាស់ចេញ និងអ្នកគ្រប់គ្រងថ្មីចូល ០១ច្បាប់

៣-លិខិតប្រកាសឱ្យបើកសេវា "ច្បាប់ដើម" ០១ច្បាប់

៤-ជីវប្រវត្តិសង្ខេបរបស់សាមីជន "មានគំរូ" ០១ច្បាប់

៥-កិច្ចសន្យារបស់សាមីជន "មានគំរូ" ០១ច្បាប់

៦-វិញ្ញាបនបត្រសុខភាព ចេញដោយក្រសួងសុខាភិបាល ឬមន្ទីរពេទ្យរដ្ឋ ០១ច្បាប់

៧-សញ្ញាប័ត្រដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ឬក្រសួងអប់រំយុវជននិងកីឡា ឬគណៈកម្មាធិការពិនិត្យវាយតម្លៃកម្រិតសញ្ញាប័ត្រ និងលិខិតបញ្ជាក់ការសិក្សា (ថតចម្លងបញ្ជាក់ពីសាលារាជធានី-ខេត្ត) ០១ច្បាប់

៨-លិខិតបញ្ជាក់ថាបានចុះឈ្មោះក្នុងបញ្ជីគណៈវិជ្ជាជីវៈ ០១ច្បាប់

៩-លិខិតថ្កោលទោស ចំពោះអ្នកមិនបម្រើការងាររដ្ឋ ០១ច្បាប់

១០- រូបថតសាមីជន (បច្ចុប្បន្ន) ៤ X ៦ ស.ម ចំនួន ០៧ សន្លឹក

១១-សាមីជនត្រូវបំពេញសំណុំលិខិតខាងលើ ហើយបញ្ជូនមកនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត។



13

ប្រការ ១១.-

អាចបើកបន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះមុននិងក្រោយសម្រាល (Cabinet de consultation pré et post natale) បានចំពោះតែ ឆ្មបមធ្យម ដែលបានចុះឈ្មោះជាសមាជិកគណៈឆ្មប និងគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

១-មានស្លាកសញ្ញាជាបន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល

២-មានកន្លែងរង់ចាំ ដែលមានទំហំយ៉ាងតូច ៨ម$^2$ និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៣-មានសៀវភៅសម្រាប់កត់ត្រាពីសកម្មភាពនៃការពិគ្រោះស្ត្រីមានផ្ទៃពោះប្រចាំថ្ងៃ

៤-មានបន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះដែលមានទំហំយ៉ាងតូច ១២ម$^2$

៥-មានគ្រែយ៉ាងច្រើនបំផុត២ សម្រាប់ធ្វើការពិគ្រោះនិងថែទាំ

៦-មានតារាងតម្លៃព្យាបាលជំងឺ

៧-មានឡាវ៉ាបូ និងសាប៊ូសម្រាប់លាងដៃ (បើមាន)

៨-មានឧបករណ៍រំងាប់មេរោគ

៩-មានធុងសំរាម

១០-មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងធុងសំរាមសម្រាប់ដាក់សំណល់ទូទៅ និងសំណល់ឆ្លងរោគ និងមានកន្ទោរ

១១-ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពព្យាបាលជំងឺរៀងរាល់បីខែ (០៣ខែ)ម្តង ផ្ញើមកមន្ទីរសុខាភិបាលរាជធានី-ខេត្ត

១២-បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះធ្វើការងារ :

-ផ្តល់ការថែទាំមុន និងក្រោយសម្រាល

-ពិនិត្យផ្ទៃពោះ

-អប់រំសុខភាព

-ចាក់ថ្នាំបង្ការមុន និងក្រោយសម្រាល

-អាចផ្តល់ឱសថជូនស្ត្រីមានផ្ទៃពោះ ទៅតាមវេជ្ជបញ្ជារបស់វេជ្ជបណ្ឌិតតែប៉ុណ្ណោះ

១៣-មានទូ១ដាក់ឱសថនៅក្នុងបន្ទប់ពិនិត្យជំងឺ-បរិក្ខារពេទ្យប្រើប្រាស់សមស្រប

១៤-ហាមធ្វើការរំលូតកូន និងសម្រាលកូនក្នុងបន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ

១៥-មិនអនុញ្ញាតដាក់តាំងលក់ឱសថក្នុងបន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះជាដាច់ខាត ។

ប្រការ ១២.-

អាចបើកបន្ទប់ព្យាបាលដោយចលនា (Cabinet de Kinésithérapie) បានចំពោះតែ អ្នកព្យាបាល



14 R 88

ដោយចលនា ដែលបានចុះឈ្មោះជាសមាជិកគណៈវិជ្ជាជីវៈ និងគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

១-មានស្លាកសញ្ញាជាបន្ទប់ព្យាបាលដោយចលនាត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល

២-មានកន្លែងរង់ចាំ ដែលមានទំហំយ៉ាងតូច ៨ម² និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៣-មានសៀវភៅសម្រាប់កត់ត្រាជំងឺប្រចាំថ្ងៃ

៤-មានបន្ទប់ព្យាបាលដោយចលនា ដែលមានទំហំយ៉ាងតូច ១២ម²

៥-មានគ្រែយ៉ាងច្រើនបំផុត២

៦-មានតារាងតម្លៃព្យាបាលជំងឺ

៧-មានឡាវ៉ាបូ និងសាប៊ូសម្រាប់លាងដៃ (បើមាន)

៨-មានធុងសំរាម

៩-ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពព្យាបាលជំងឺរៀងរាល់បីខែ (០៣ខែ)ម្តង ផ្ញើមកមន្ទីរសុខាភិបាលរាជធានី-ខេត្ត

១០-អ្នកព្យាបាលដោយចលនាធ្វើការងារ :

-ព្យាបាលដោយចលនាតាមវេជ្ជបញ្ជាគ្រូពេទ្យ ដើម្បីស្តារលទ្ធភាពពលកម្មជនរងគ្រោះ និងជនពិការ

-រាល់សម្ភារៈចាំបាច់សម្រាប់បម្រើការឱ្យសេវាកម្មនេះ ត្រូវធ្វើឡើងសមស្របទៅតាមស្តង់ដារ និងត្រូវរក្សាសុវត្ថិភាពដល់អ្នកជំងឺក្នុងពេលប្រើប្រាស់

-ត្រូវមានការទំនាក់ទំនងប្រឹក្សាយោបល់ជាមួយគ្រូពេទ្យ ផ្នែកវេជ្ជសាស្ត្រ សល្យសាស្ត្រ និងផ្នែកពាក់ព័ន្ធដទៃទៀត ដើម្បីឱ្យមានប្រសិទ្ធិភាពក្នុងការព្យាបាល

-ត្រូវគោរពសិទ្ធិអ្នកជំងឺជាមូលដ្ឋាន និងត្រូវផ្តល់ព័ត៌មានជាមុនដល់អ្នកជំងឺ អំពីរបៀបព្យាបាល

-ត្រូវធ្វើការព្យាបាលក្នុងបរិយាកាសមួយ ដែលមានសុវត្ថិភាពដល់អ្នកជំងឺ ព្រមទាំងផ្តល់ការប្រឹក្សាដល់អ្នកជំងឺ

១១-មានទូ១ដាក់ឱសថនៅក្នុងបន្ទប់ពិនិត្យជំងឺ-បរិក្ខារពេទ្យប្រើប្រាស់សមស្រប

១២-ហាមធ្វើការព្យាបាលដោយពុំសមស្របក្រៅពីសមត្ថភាពចំណេះដឹងរបស់ខ្លួន

១៣-មិនអនុញ្ញាតដាក់តាំងលក់ឱសថក្នុងបន្ទប់ពិគ្រោះព្យាបាលជំងឺជាដាច់ខាត ។

ប្រការ ១៣.-

អាចបើកបន្ទប់ថែទាំជំងឺ (Cabinet de Soins) បានចំពោះតែ គិលានុបដ្ឋាក-យិកាមធ្យម ដែលបានចុះឈ្មោះជាសមាជិកគណៈ គិលានុបដ្ឋាក-យិកា និងគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

១-មានស្លាកសញ្ញាជាបន្ទប់ថែទាំជំងឺត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខា

ភិបាល

២-មានកន្លែងរង់ចាំ ដែលមានទំហំយ៉ាងតូច ៨ម$^2$ និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៣-មានសៀវភៅសម្រាប់កត់ត្រាពីសកម្មភាពនៃការថែទាំជំងឺប្រចាំថ្ងៃ

៤-មានបន្ទប់ថែទាំជំងឺដែលមានទំហំយ៉ាងតូច ១២ម$^2$

៥-មានគ្រែយ៉ាងច្រើនបំផុត២

៦-មានតារាងតម្លៃព្យាបាលជំងឺ

៧-មានឡាវ៉ាបូ និងសាប៊ូសម្រាប់លាងដៃ (បើមាន)

៨-មានឧបករណ៍រំងាប់មេរោគ

៩-មានធុងសំរាម

១០-មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងធុងសំរាមសម្រាប់ដាក់សំណល់ទូទៅ និងសំណល់ឆ្លងរោគ និងមានកន្ត្រៃ

១១-ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពព្យាបាលជំងឺរៀងរាល់បីខែ (០៣ខែ)ម្តង ផ្ញើមកមន្ទីរសុខាភិបាលរាជធានី-ខេត្ត

១២-បន្ទប់ថែទាំជំងឺធ្វើការងារ :

-ថែទាំអ្នកជំងឺតាមវេជ្ជបញ្ជា និងជំបូន្មានពីគ្រូពេទ្យ

-លាងសំអាតរុំរបួសជូនអ្នកជំងឺ

-ផ្តល់ឱសថតាមវេជ្ជបញ្ជារបស់គ្រូពេទ្យ

-តាមដានការវិវត្តន៍ជំងឺ ដើម្បីធ្វើការបញ្ជូនបន្តទៅសេវាទទួលខុសត្រូវក្នុងការព្យាបាល

-ត្រូវមានទំនាក់ទំនងជិតស្និទ្ធជាមួយគ្រូពេទ្យ

-អនុវត្តការថែទាំជំងឺ ទៅតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល

១៣-មានទូ១ដាក់ឱសថនៅក្នុងបន្ទប់ពិនិត្យជំងឺ-បរិក្ខារពេទ្យប្រើប្រាស់សមស្រប

១៤-មិនអនុញ្ញាតដាក់តាំងលក់ឱសថក្នុងបន្ទប់ថែទាំជំងឺជាដាច់ខាត។

ប្រការ ១៥.-

អាចបើកបន្ទប់ពិគ្រោះព្យាបាលជំងឺបានចំពោះតែ វេជ្ជបណ្ឌិត ឬគ្រូពេទ្យមធ្យម ដែលបានចុះឈ្មោះជាសមាជិកគណៈគ្រូពេទ្យ ត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

១-មានស្លាកសញ្ញាជាបន្ទប់ពិគ្រោះជំងឺត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល

២-មានកន្លែងរង់ចាំ ដែលមានទំហំយ៉ាងតូច ៨ម$^2$ និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៣-មានសៀវភៅសម្រាប់កត់ត្រាជំងឺប្រចាំថ្ងៃ

16 

៤-មានបន្ទប់ពិគ្រោះព្យាបាលជំងឺ ដែលមានទំហំយ៉ាងតូច ១២ម$^2$

៥-មានគ្រែព្យាបាលជំងឺយ៉ាងច្រើនបំផុត២

៦-មានតារាងតម្លៃព្យាបាលជំងឺ

៧-មានឡាវ៉ាបូ និងសាប៊ូសម្រាប់លាងដៃ (បើមាន)

៨-មានឧបករណ៍រំងាប់មេរោគ

៩-មានធុងសំរាម

១០-មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងធុងសំរាមសម្រាប់ដាក់សំណល់ទូទៅ និងសំណល់ឆ្លងរោគ និងមានកន្ត្រៃ

១១-មានទូ១ដាក់ឱសថនៅក្នុងបន្ទប់ពិនិត្យជំងឺ និងបរិក្ខារពេទ្យប្រើប្រាស់សមស្រប

១២-ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពព្យាបាលជំងឺរៀងរាល់បីខែ (០៣ខែ)ម្តង ផ្ញើមកមន្ទីរសុខាភិបាលរាជធានី-ខេត្ត

១៣-មិនអនុញ្ញាតឱ្យមានអ្នកជំងឺសម្រាកលើសពី២៤ម៉ោង

១៤-មិនអនុញ្ញាតដាក់តាំងលក់ឱសថក្នុងបន្ទប់ពិគ្រោះព្យាបាលជំងឺជាដាច់ខាត។

## ប្រការ ១៥.-

អាចបើកបន្ទប់ពិគ្រោះព្យាបាលជំងឺមាត់-ធ្មេញបានចំពោះតែ ទន្តបណ្ឌិត ឬទន្តពេទ្យ ដែលបានចុះឈ្មោះជាសមាជិកគណៈទន្តពេទ្យ និងគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

១-មានស្លាកសញ្ញាជាបន្ទប់ពិគ្រោះព្យាបាលជំងឺមាត់-ធ្មេញត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល

២-មានកន្លែងរង់ចាំ ដែលមានទំហំយ៉ាងតូច ៨ម$^2$ និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៣-មានសៀវភៅសម្រាប់កត់ត្រាជំងឺប្រចាំថ្ងៃ

៤-មានបន្ទប់ពិគ្រោះជំងឺមាត់-ធ្មេញ ដែលមានទំហំយ៉ាងតូច ១២ម$^2$

៥-មានកៅអីធ្មេញ១ ដោយមានពន្លឺអគ្គិសនីសម្រាប់បំភ្លឺត្រឹមត្រូវ និងមានទឹកស្អាតខ្ពុរមាត់

៦-មានបន្ទប់ចាក់ពុម្ពធ្មេញសមរម្យ (បើមាន)

៧-មានម៉ាស៊ីនកាំរស្មី X ថតធ្មេញខ្នាតតូច ដោយរៀបចំឱ្យបានសមស្របតាមលក្ខណៈបច្ចេកទេសនៃការថតឆ្លុះ (បើមាន)

៨-មានឡាវ៉ាបូ និងសាប៊ូសម្រាប់លាងដៃ (បើមាន)

៩-មានឧបករណ៍រំងាប់មេរោគ

១០-មានធុងសំរាម

១១-មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងធុងសំរាមសម្រាប់ដាក់សំណល់ទូទៅ និងសំណល់

ឆ្លងរោគ និងមានកន្ត្រៃ

១២-មានទូ១ដាក់ឱសថនៅក្នុងបន្ទប់ពិនិត្យជំងឺ និងបរិក្ខារពេទ្យប្រើប្រាស់សមស្រប

១៣-មានតារាងតម្លៃព្យាបាលជំងឺ

១៤-ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពព្យាបាលជំងឺរៀងរាល់បីខែ (០៣ខែ)ម្តង ផ្ញើមកមន្ទីរសុខាភិបាលរាជធានី-ខេត្ត

១៥-មិនអនុញ្ញាតដាក់តាំងលក់ឱសថក្នុងបន្ទប់ពិគ្រោះព្យាបាលជំងឺមាត់-ធ្មេញជាដាច់ខាត។

ប្រការ ១៦.-

អាចបើកបន្ទប់ពិគ្រោះព្យាបាលជំងឺភ្នែកបានចំពោះតែ វេជ្ជបណ្ឌិត ឬគ្រូពេទ្យមធ្យម ដែលមានបទពិសោធន៍ផ្នែកចក្ខុរោគនិងបានចុះឈ្មោះជាសមាជិកគណៈគ្រូពេទ្យ និងត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ:

១-មានស្លាកសញ្ញាជាបន្ទប់ពិគ្រោះព្យាបាលជំងឺភ្នែកត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល

២-មានកន្លែងរង់ចាំ ដែលមានទំហំយ៉ាងតិច ៨ម² និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៣-មានសៀវភៅសម្រាប់កត់ត្រាជំងឺប្រចាំថ្ងៃ

៤-មានបន្ទប់ពិគ្រោះជំងឺភ្នែក ដែលមានទំហំយ៉ាងតិច ១២ម²

៥-មានគ្រែព្យាបាលជំងឺយ៉ាងច្រើនបំផុត២

៦-មានឡាវ៉ាបូ និងសាប៊ូសម្រាប់លាងដៃ (បើមាន)

៧-មានឧបករណ៍វាស់ម៉េហោត

៨-មានធុងសំរាម

៩-មានឧបករណ៍ឆ្លុះភ្នែក (Ophtalmoscope)

១០-មានផ្ទាំងអក្សរ E សម្រាប់វាស់ភ្នែក

១១-មានពិល

១២-មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងធុងសំរាមសម្រាប់ដាក់សំណល់ទូទៅ និងសំណល់ឆ្លងរោគ និងមានកន្ត្រៃ

១៣-មានទូ១ដាក់ឱសថនៅក្នុងបន្ទប់ពិនិត្យជំងឺ-បរិក្ខារពេទ្យប្រើប្រាស់សមស្រប

១៤-មានតារាងតម្លៃព្យាបាលជំងឺ

១៥-ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពព្យាបាលជំងឺរៀងរាល់បីខែ (០៣ខែ)ម្តង ផ្ញើមកមន្ទីរសុខាភិបាលរាជធានី-ខេត្ត

១៦-មិនអនុញ្ញាតដាក់តាំងលក់ឱសថក្នុងបន្ទប់ពិគ្រោះព្យាបាលជំងឺភ្នែកជាដាច់ខាត។

18

ប្រការ ១៧.-

អាចបើកបន្ទប់ពិគ្រោះព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់កបានចំពោះតែ វេជ្ជបណ្ឌិត ឬគ្រូពេទ្យមធ្យម ដែលមានបទ ពិសោធន៍ផ្នែកត្រចៀក-ច្រមុះ-បំពង់ក និងបានចុះឈ្មោះជាសមាជិកគណៈគ្រូពេទ្យ និងគោរពតាម ល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

១-មានស្លាកសញ្ញាជាបន្ទប់ពិគ្រោះព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់កត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល

២-មានកន្លែងរង់ចាំ ដែលមានទំហំយ៉ាងតិច ៨ម៉ែ២ និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៣-មានសៀវភៅសម្រាប់កត់ត្រាជំងឺប្រចាំថ្ងៃ

៤-មានបន្ទប់ពិគ្រោះជំងឺត្រចៀក-ច្រមុះ-បំពង់ក ដែលមានទំហំយ៉ាងតូច ១២ម៉ែ២

៥-មានឡាវ៉ាបូ និងសាប៊ូសម្រាប់លាងដៃ (បើមាន)

៦-មានគ្រែព្យាបាលជំងឺយ៉ាងច្រើនបំផុត២

៧-មានឧបករណ៍រំងាប់មេរោគ

៨-មានធុងសំរាម

៩-មានប្រដាប់ពិនិត្យត្រចៀក-ច្រមុះ (Otoscope)

១០-មានប្រដាប់ពិនិត្យបំពង់ក (Laryngoscope)

១១-មានពិល

១២-មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងធុងសំរាមសម្រាប់ដាក់សំណល់ទូទៅ និងសំណល់ឆ្លងរោគ និងមានកន្ត្រោរ

១៣-មានទូ១ដាក់ឱសថនៅក្នុងបន្ទប់ពិនិត្យជំងឺ-បរិក្ខារពេទ្យប្រើប្រាស់សមស្រប

១៤-មានតារាងតម្លៃព្យាបាលជំងឺ

១៥-ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពព្យាបាលជំងឺរៀងរាល់បីខែ (០៣ខែ)ម្តង ផ្ញើមកមន្ទីរសុខាភិបាលរាជធានី-ខេត្ត

១៦-មិនអនុញ្ញាតដាក់តាំងលក់ឱសថក្នុងបន្ទប់ពិគ្រោះព្យាបាលជំងឺក្នុងជាដាច់ខាត។

ប្រការ ១៨.-

អាចបើកបន្ទប់ពិគ្រោះព្យាបាលជំងឺសើស្បែកបានចំពោះតែ វេជ្ជបណ្ឌិត ឬគ្រូពេទ្យមធ្យម ដែលមានបទពិសោធន៍ផ្នែកជំងឺសើស្បែកនិងបានចុះឈ្មោះជាសមាជិកគណៈគ្រូពេទ្យនិងគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ:

១-មានស្លាកសញ្ញាជាបន្ទប់ពិគ្រោះព្យាបាលជំងឺសើស្បែកត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល

២-មានកន្លែងរង់ចាំ ដែលមានទំហំយ៉ាងតិច ៨ម៉ែ២ និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៣-មានសៀវភៅសម្រាប់កត់ត្រាជំងឺប្រចាំថ្ងៃ

៤-មានបន្ទប់ពិគ្រោះជំងឺសើស្បែក ដែលមានទំហំយ៉ាងតិច ១២ម$^{2}$

៥-មានឡាវ៉ាបូ និងសាប៊ូសម្រាប់លាងដៃ (បើមាន)

៦-មានគ្រែព្យាបាលជំងឺយ៉ាងច្រើនបំផុត២

៧-មានឧបករណ៍រំងាប់មេរោគ

៨-មានធុងសំរាម

៩-មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងធុងសំរាមសម្រាប់ដាក់សំណល់ទូទៅ និងសំណល់ឆ្លងរោគ និងមានកន្ត្រៃ

១០-មានទូ១ដាក់ឱសថនៅក្នុងបន្ទប់ពិនិត្យជំងឺ-បរិក្ខារពេទ្យប្រើប្រាស់សមស្រប

១១-មានតារាងតម្លៃព្យាបាលជំងឺ

១២-ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពព្យាបាលជំងឺរៀងរាល់បីខែ (០៣ខែ) ម្តង ផ្ញើមកមន្ទីរសុខាភិបាលរាជធានី-ខេត្ត

១៣-មិនអនុញ្ញាតដាក់តាំងលក់ឱសថក្នុងបន្ទប់ពិគ្រោះព្យាបាលជំងឺសើស្បែកជាដាច់ខាត។

ប្រការ ១៩.-

អាចបើកបន្ទប់ពិគ្រោះព្យាបាលជំងឺផ្លូវចិត្តបានចំពោះតែ វេជ្ជបណ្ឌិត ឬគ្រូពេទ្យមធ្យម ដែលមានបទពិសោធន៍ផ្នែកជំងឺផ្លូវចិត្ត និងបានចុះឈ្មោះជាសមាជិកគណៈគ្រូពេទ្យ និងគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

១-មានស្លាកសញ្ញាជាបន្ទប់ពិគ្រោះព្យាបាលជំងឺសុខភាពផ្លូវចិត្តត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល

២-មានកន្លែងរង់ចាំ ដែលមានទំហំយ៉ាងតិច ៨ម$^{2}$ និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៣-មានសៀវភៅសម្រាប់កត់ត្រា ពីសកម្មភាពនៃការពិនិត្យព្យាបាលជំងឺប្រចាំថ្ងៃ

៤-មានបន្ទប់ពិគ្រោះជំងឺសុខភាពផ្លូវចិត្ត ដែលមានទំហំយ៉ាងតិច ១២ម$^{2}$

៥-មានឡាវ៉ាបូ និងសាប៊ូសម្រាប់លាងដៃ

៦-មានគ្រែព្យាបាលជំងឺយ៉ាងច្រើនបំផុត២

៧-មានឧបករណ៍រំងាប់មេរោគ

៨-មានធុងសំរាម

៩-មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងធុងសំរាមសម្រាប់ដាក់សំណល់ទូទៅ និងសំណល់ឆ្លងរោគ និងមានកន្ត្រៃ

១០-មានទូ១ដាក់ឱសថនៅក្នុងបន្ទប់ពិនិត្យជំងឺ-បរិក្ខារពេទ្យប្រើប្រាស់សមស្រប

១១-មានតារាងតម្លៃព្យាបាលជំងឺ



20

១២-ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពព្យាបាលជំងឺរៀងរាល់បីខែ (០៣ខែ)ម្តង ផ្ញើមកមន្ទីរសុខាភិបាលរាជធានី-ខេត្ត

១៣-មិនអនុញ្ញាតដាក់តាំងលក់ឱសថក្នុងបន្ទប់ពិគ្រោះព្យាបាលជំងឺផ្លូវចិត្តជាដាច់ខាត។

ប្រការ ២០.-

អាចបើកមន្ទីរព្យាបាលជំងឺមាត់-ធ្មេញបានចំពោះតែ ទន្តបណ្ឌិត ដែលចូលនិវត្តន៍ ឬបោះបង់ការងាររដ្ឋ ឬផ្អាកការងាររដ្ឋដោយគ្មានបៀវត្ស ដែលបញ្ជាក់ដោយប្រធានស្ថាប័នសាមី។ ចំពោះអ្នកមិនបម្រើការងាររដ្ឋ ត្រូវមានបទពិសោធន៍វិជ្ជាជីវៈយ៉ាងតិច៥ឆ្នាំ បញ្ជាក់ដោយអង្គភាពសាមី និងត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោមនេះ ៖

១-មានអាគារធម្មតា ១ជាន់ ឬច្រើនជាន់ សមរម្យជាមន្ទីរព្យាបាលមាត់-ធ្មេញ

២-មានស្លាកសញ្ញាមន្ទីរព្យាបាលជំងឺមាត់-ធ្មេញត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល

៣-មានកន្លែងរង់ចាំ ១៦ម$^2$ យ៉ាងតិច និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៤-មានសៀវភៅសម្រាប់កត់ត្រាជំងឺប្រចាំថ្ងៃ

៥-មានបន្ទប់ពិគ្រោះជំងឺមាត់-ធ្មេញ

៦-មានកៅអីព្យាបាលមាត់-ធ្មេញចាប់ពី៣ឡើងទៅ

៧-មានកៅអីព្យាបាលមាត់-ធ្មេញនីមួយៗត្រូវមានទន្តបណ្ឌិត ឬទន្តពេទ្យម្នាក់ និងជំនួយការម្នាក់

៨-មានបំពង់អុកស៊ីសែន និងឧបករណ៍សម្រាប់សង្គ្រោះបន្ទាន់ (បើមាន)

៩-មានបន្ទប់រំងាប់មេរោគ ដែលបំពាក់ដោយប្រដាប់រំងាប់មេរោគត្រឹមត្រូវ

១០-មានទូរដាក់ឱសថ និងបរិក្ខារពេទ្យគ្រប់គ្រាន់សម្រាប់ព្យាបាល

១១-មានម៉ាស៊ីនសំអាតធ្មេញ

១២-មានម៉ាស៊ីនព្យាបាលរន្ធធ្មេញ ឬសធ្មេញ

១៣-មានម៉ាស៊ីនឆ្លុះធ្មេញក្នុងមាត់ (បើមាន)

១៤-មានបន្ទប់ចាក់ពុម្ពធ្មេញ និងធ្វើធ្មេញសិប្បនិម្មិត

១៥-មានម៉ាស៊ីនកាំរស្មី X ថតធ្មេញខ្នាតតូច ឬធំ (Panoramix)ដោយរៀបចំដាក់ក្នុងបន្ទប់ទំហំយ៉ាងហោច១២ម$^2$ មានជញ្ជាំងនិងទ្វារពាសសំណកម្រាស់ពី ១មម ដល់ ៣មម ស្របតាមលក្ខណៈបច្ចេកទេស

១៦-ករណីធ្វើការវះកាត់មាត់-ធ្មេញ ត្រូវមានបន្ទប់វះកាត់បំពាក់ដោយឧបករណ៍គ្រប់គ្រាន់សមស្រប

១៧-មានឃ្លាំងដាក់សំភារៈ ព្រមទាំងបំពង់ពន្លត់អគ្គីភ័យ

១៨-មានម៉ាស៊ីនភ្លើងបម្រុងសម្រាប់ប្រើប្រាស់ពេលដាច់ចរន្តម្តងៗ

១៩-មានសំភារៈព្យាបាលសម្រាប់អ្នកជំងឺម្នាក់ៗ មិនត្រូវប្រើប្រាស់សម្ភារៈរួមគ្នាទេ



21

២០-មានឯកសារអ្នកជំងឺ (Dossier des malades) និងរក្សាទុកឱ្យបានត្រឹមត្រូវ

២១-មានតារាងតម្លៃព្យាបាល

២២-ត្រូវផ្តល់របាយការណ៍អំពីសកម្មភាពព្យាបាលជំងឺឱ្យបានទៀងទាត់រៀងរាល់បីខែ (០៣ខែ) ម្តង ផ្ញើមកនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាលតាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត

២៣-មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួចនិងធុងសំរាមសម្រាប់ដាក់សំណល់ទូទៅ និងសំណល់ឆ្លងរោគ និងបែងចែកទៅតាមប្រភេទសំណល់ ដែលបានកំណត់ដោយសេចក្តីណែនាំនៃក្រសួងសុខាភិបាល

២៤-មានប្រព័ន្ធទំនាក់ទំនងជាមួយមន្ទីរពេទ្យដែលមានឡសម្រាប់ដុតកម្ទេចកាកសំណល់ប្រើប្រាស់ ។

## ប្រការ ២១.-

អាចបើកមន្ទីរពិសោធន៍វេជ្ជសាស្ត្របានចំពោះតែ ឱសថបណ្ឌិត ឬឱសថការីឧត្តម ឬវេជ្ជបណ្ឌិត ដែលមានបទពិសោធន៍ផ្នែកមន្ទីរពិសោធន៍ ដែលចូលនិវត្តន៍ ឬបោះបង់ការងាររដ្ឋ ឬផ្អាកការងាររដ្ឋដោយគ្មានបៀវត្ស ដែលបញ្ជាក់ដោយប្រធានស្ថាប័នសាមី ។ ចំពោះអ្នកមិនបម្រើការងាររដ្ឋ ត្រូវមានបទពិសោធន៍វិជ្ជាជីវៈយ៉ាងតិច៥ឆ្នាំ បញ្ជាក់ដោយអង្គភាពសាមី និងបានចុះឈ្មោះជាសមាជិកគណៈវិជ្ជាជីវៈ និងត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

១-មានអាគារធម្មតា ១ជាន់ ឬច្រើនជាន់ សមរម្យជាមន្ទីរពិសោធន៍

២-មានស្លាកសញ្ញាមន្ទីរពិសោធន៍វេជ្ជសាស្ត្រត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល

៣-មានកន្លែងរង់ចាំ ១៦ម$^{២}$ យ៉ាងតិច និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៤-មានសៀវភៅសម្រាប់កត់ត្រាពីសកម្មភាពនៃការពិនិត្យឈាមប្រចាំថ្ងៃ

៥-មានបន្ទប់ពិគ្រោះទំហំយ៉ាងតិច ១២ម$^{២}$

៦-មានគ្រែសម្រាប់បូមឈាម និងធ្វើបុរេសម្ភេទន៍ (Prélèvement)

៧-មានធុងសំរាមតាមគ្រែនីមួយៗ

៨-មានទូទឹកកកដាក់សូលុយស្យុងរ៉េអាក់ទីហ្វ និងឧបករណ៍ចាំបាច់ក្នុងការប្រើប្រាស់ផ្នែកការងារពិសោធន៍សមស្រប ១ ឬ ២

៩-មីក្រូទស្សន៍ ១ ឬ ច្រើន

១០-មានឧបករណ៍ទំនើបផ្សេងៗសម្រាប់ការងារមន្ទីរពិសោធន៍

១១-មានឃ្លាំង ឬទូរថ្នាក់ៗដាក់សំភារៈ និងប្រតិករ

១២-មានបន្ទប់រំងាប់មេរោគ ដែលបំពាក់ដោយប្រដាប់រំងាប់មេរោគត្រឹមត្រូវ

១៣-មានបន្ទប់ទឹក និងបង្គន់អនាម័យ មានប្រព័ន្ធសម្លាប់មេរោគក្នុងទឹក ឬកាកសំណល់មុននឹងបង្ហូរចូលប្រព័ន្ធលូទឹកស្អុយ

១៤-មានតារាងតម្លៃពិនិត្យ

១៥-ត្រូវផ្តល់របាយការណ៍អំពីសកម្មភាពព្យាបាលជំងឺឱ្យបានទៀងទាត់រៀងរាល់បីខែ (០៣ខែ) ម្តង ផ្ញើមកនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាលតាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត

១៦-មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងធុងសំរាមសម្រាប់ដាក់សំណល់ទូទៅ និងសំណល់ឆ្លងរោគ និងបែងចែកទៅតាមប្រភេទសំណល់ ដែលបានកំណត់ដោយសេចក្តីណែនាំនៃក្រសួងសុខាភិបាល

១៧-មានប្រព័ន្ធទំនាក់ទំនងជាមួយមន្ទីរពេទ្យដែលមានឡសម្រាប់ដុតកម្ទេចកាកសំណល់ប្រើប្រាស់។

## ប្រការ ២២.-

អាចបើកមន្ទីរសម្រាកព្យាបាលជំងឺភ្នែកបានចំពោះតែ វេជ្ជបណ្ឌិត ដែលចូលនិវត្តន៍ ឬបោះបង់ការងាររដ្ឋ ឬផ្អាកការងាររដ្ឋដោយគ្មានបៀវត្ស ដែលបញ្ជាក់ដោយប្រធានស្ថាប័នសាមី។ ចំពោះអ្នកមិនបម្រើការងាររដ្ឋ ត្រូវមានបទពិសោធន៍វិជ្ជាជីវៈយ៉ាងតិច៥ឆ្នាំ បញ្ជាក់ដោយអង្គភាពសាមី និងបានចុះឈ្មោះជាសមាជិកគណៈគ្រូពេទ្យ និងត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

១-មានអាគារសមរម្យជាមន្ទីរសម្រាកព្យាបាលជំងឺភ្នែក

២-មានស្លាកសញ្ញាមន្ទីរព្យាបាលជំងឺភ្នែកត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល

៣-មានកន្លែងរង់ចាំ ២៤ម$^{២}$ យ៉ាងតិច និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៤-មានបន្ទប់ពិគ្រោះជំងឺ ដែលមានទំហំយ៉ាងតិច ១២ម$^{២}$

៥-មានសៀវភៅសម្រាប់កត់ត្រាពីសកម្មភាពជំងឺប្រចាំថ្ងៃ

៦-ក្របខ័ណ្ឌបច្ចេកទេស និងអ្នកបម្រើការងារទូទៅគឺ

- សរុប ០.៧ បុគ្គលិក សម្រាប់គ្រែ ១ (កម្រិតទាបបំផុត)
- បុគ្គលិកបច្ចេកទេសមានសញ្ញាប័ត្រលើសពី ៥០% នៃចំនួនបុគ្គលិកសរុប

៧-ត្រូវមានគ្រែយ៉ាងតិចបំផុត ១០គ្រែ យ៉ាងច្រើន ២០គ្រែ សម្រាប់អ្នកជំងឺសម្រាកព្យាបាល

៨-មានបន្ទប់ពិនិត្យជំងឺ និងសំភារៈគ្រប់គ្រាន់

៩-មានឧបករណ៍ឆ្លុះភ្នែក (Ophtalmoscope)

១០-មានផ្ទាំងអក្សរ E សម្រាប់វាស់ភ្នែក

១១-មានពិល

១២-មានបន្ទប់សម្រាប់អ្នកជំងឺសម្រាកត្រឹមត្រូវ

១៣-មានបន្ទប់គ្រូពេទ្យ និងមានគ្រូពេទ្យប្រចាំការអចិន្ត្រៃយ៍

១៤-មានទូរដាក់ឱសថសំភារៈ-បរិក្ខារពេទ្យ សម្រាប់ប្រើប្រាស់សមស្រប

១៥-មានបន្ទប់រំងាប់មេរោគ ដែលបំពាក់ដោយឧបករណ៍រំងាប់មេរោគត្រឹមត្រូវ



23 p. 15

១៦-មានប្រង់ការ វេទះរុញយ៉ាងតិច១ តាមជាន់នីមួយៗ

១៧-មានឧបករណ៍សម្លាប់មេរោគយ៉ាងតិច១

១៨-មានឃ្លាំងដាក់សំភារ:

១៩-មានម៉ាស៊ីនភ្លើងបម្រុងសម្រាប់ប្រើប្រាស់ពេលដាច់ចរន្តម្តងៗ

២០-មានបន្ទប់ទឹក និងបង្គន់អនាម័យស្អាត

២១-មានប្រដាប់ពន្លត់អគ្គីភ័យ

២២-មានបន្ទប់វះកាត់ ត្រូវរៀបចំសមស្របតាមលក្ខណៈបច្ចេកទេស និងសេចក្តីណែនាំដែលមានចែងក្នុងស្តង់ដារសេវាឯកជនរបស់ក្រសួងសុខាភិបាល

២៣-មានឯកសារអ្នកជំងឺ (Dossier des malades)

២៤-មានតារាងតម្លៃព្យាបាល

២៥-ត្រូវផ្តល់របាយការណ៍អំពីសកម្មភាពព្យាបាលជំងឺឱ្យបានទៀងទាត់រៀងរាល់បីខែ (០៣ខែ) ម្តង ផ្ញើមកនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត

២៦-មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងថង់សំរាមសម្រាប់ដាក់សំណល់ទូទៅ និងសំណល់ឆ្លងរោគ និងបែងចែកទៅតាមប្រភេទសំណល់ ដែលបានកំណត់ដោយសេចក្តីណែនាំនៃក្រសួងសុខាភិបាល

២៧-មានប្រព័ន្ធទំនាក់ទំនងជាមួយមន្ទីរពេទ្យដែលមានឡសម្រាប់ដុតកាកសំណល់ផ្សេងៗ ។

ប្រការ ២៣.-

អាចបើកមន្ទីរសម្រាកព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់កបានចំពោះតែ វេជ្ជបណ្ឌិត ដែលចូលនិវត្តន៍ ឬបោះបង់ការងាររដ្ឋ ឬផ្អាកការងាររដ្ឋដោយគ្មានបៀវត្ស ដែលបញ្ជាក់ដោយប្រធានស្ថាប័នសាមី។ ចំពោះអ្នកមិនបម្រើការងាររដ្ឋ ត្រូវមានបទពិសោធនវិជ្ជាជីវៈយ៉ាងតិច៥ឆ្នាំ បញ្ជាក់ដោយអង្គភាពសាមី និងបានចុះឈ្មោះជាសមាជិកគណៈគ្រូពេទ្យ និងត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

១-មានអគារសមរម្យជាមន្ទីរសម្រាកព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់ក

២-មានស្លាកសញ្ញាមន្ទីរសម្រាកព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់កត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល

៣-មានកន្លែងរង់ចាំ ២៤$m^2$ យ៉ាងតិច និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៤-មានបន្ទប់ពិគ្រោះជំងឺ ដែលមានទំហំយ៉ាងតិច ១២$m^2$

៥-មានសៀវភៅសម្រាប់កត់ត្រាពីសកម្មភាពជំងឺប្រចាំថ្ងៃ

៦-ក្របខ័ណ្ឌបច្ចេកទេស និងអ្នកបម្រើការងារទូទៅគឺ

- សរុប ០.៧ បុគ្គលិក សម្រាប់គ្រែ ១ (កំរិតទាបបំផុត)
- បុគ្គលិកបច្ចេកទេសមានសញ្ញាប័ត្រលើសពី ៥០% នៃចំនួនបុគ្គលិកសរុប

24

៧-ត្រូវមានគ្រែយ៉ាងតិចបំផុត ១០គ្រែ យ៉ាងច្រើន ២០គ្រែ សម្រាប់អ្នកជំងឺសម្រាកព្យាបាល

៨-មានបន្ទប់ពិនិត្យជំងឺ និងសំភារៈគ្រប់គ្រាន់

៩-មានប្រដាប់ពិនិត្យត្រចៀក-ច្រមុះ (Otoscope)

១០-មានប្រដាប់ពិនិត្យបំពង់ក (Laryngoscope)

១១-មានពិល

១២-មានបន្ទប់សម្រាប់អ្នកជំងឺសម្រាកត្រឹមត្រូវ

១៣-មានបន្ទប់គ្រូពេទ្យ និងមានគ្រូពេទ្យប្រចាំការអចិន្ត្រៃយ៍

១៤-មានទូរដាក់ឱសថសំភារៈ-បរិក្ខារពេទ្យ សម្រាប់ប្រើប្រាស់សមស្រប

១៥-មានបន្ទប់រំងាប់មេរោគ ដែលបំពាក់ដោយឧបករណ៍រំងាប់មេរោគត្រឹមត្រូវ

១៦-មានប្រងំការ រទេះរុញយ៉ាងតិច១ តាមជាន់នីមួយៗ

១៧-មានឧបករណ៍សម្លាប់មេរោគយ៉ាងតិច១

១៨-មានឃ្លាំងដាក់សំភារៈ

១៩-មានម៉ាស៊ីនភ្លើងបម្រុងសម្រាប់ប្រើប្រាស់ពេលដាច់ចរន្តម្តងៗ

២០-មានបន្ទប់ទឹក និងបង្គន់អនាម័យស្អាត

២១-មានប្រដាប់ពន្លត់អគ្គីភ័យ

២២-មានបន្ទប់វះកាត់ ត្រូវរៀបចំសមស្របតាមលក្ខណៈបច្ចេកទេស និងសេចក្តីណែនាំដែលមានចែងក្នុងស្តង់ដារសេវាឯកជនរបស់ក្រសួងសុខាភិបាល

២៣-មានឯកសារអ្នកជំងឺ (Dossier des malades)

២៤-មានតារាងតម្លៃព្យាបាល

២៥-ត្រូវផ្តល់របាយការណ៍អំពីសកម្មភាពព្យាបាលជំងឺឱ្យបានទៀងទាត់រៀងរាល់បីខែ (០៣ខែ)ម្តង ផ្ញើមកនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាលតាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត

២៦-មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងធុងសំរាមសម្រាប់ដាក់សំណល់ទូទៅ និងសំណល់ឆ្លងរោគ និងបែងចែកទៅតាមប្រភេទសំណល់ ដែលបានកំណត់ដោយសេចក្តីណែនាំនៃក្រសួងសុខាភិបាល

២៧-មានប្រព័ន្ធទំនាក់ទំនងជាមួយមន្ទីរពេទ្យដែលមានឡសម្រាប់ដុតកាកសំណល់ផ្សេងៗ ។

## ប្រការ ២៨.-

អាចបើកមន្ទីរសម្រាកព្យាបាលជំងឺសើស្បែកបានចំពោះតែ វេជ្ជបណ្ឌិត ដែលចូលនិវត្តន៍ ឬបោះបង់ការងាររដ្ឋ ឬផ្អាកការងាររដ្ឋដោយគ្មានបៀវត្ស ដែលបញ្ជាក់ដោយប្រធានស្ថាប័នសាមី។ ចំពោះអ្នកមិនបម្រើការងាររដ្ឋ ត្រូវមានបទពិសោធន៍វិជ្ជាជីវៈយ៉ាងតិច៥ឆ្នាំ បញ្ជាក់ដោយអង្គភាពសាមី និងបានចុះឈ្មោះជាសមាជិកគណៈគ្រូពេទ្យ និងត្រូវគោរពតាមល័ក្ខខ័ណ្ឌ ដូចខាងក្រោមនេះ :

១-មានអាគារសមរម្យជាមន្ទីរសម្រាកព្យាបាលជំងឺសើស្បែក

២-មានស្លាកសញ្ញាមន្ទីរសម្រាកព្យាបាលជំងឺសើស្បែកត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល

៣-មានកន្លែងរង់ចាំ ២៤ម$^{2}$ យ៉ាងតិច និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៤-មានបន្ទប់ពិគ្រោះជំងឺ ដែលមានទំហំយ៉ាងតិច ១២ម$^{2}$

៥-មានសៀវភៅសម្រាប់កត់ត្រាពីសកម្មភាពជំងឺប្រចាំថ្ងៃ

៦-ក្របខ័ណ្ឌបច្ចេកទេស និងអ្នកបម្រើការងារទូទៅគឺ

- សរុប ០,៧ បុគ្គលិក សម្រាប់គ្រែ ១ (កម្រិតទាប)
- បុគ្គលិកបច្ចេកទេសមានសញ្ញាប័ត្រលើសពី ៥០% នៃចំនួនបុគ្គលិកសរុប

៧-ត្រូវមានគ្រែយ៉ាងតិចបំផុត ១០គ្រែ យ៉ាងច្រើន ២០គ្រែ សម្រាប់អ្នកជំងឺសម្រាកព្យាបាល

៨-មានបន្ទប់ពិនិត្យជំងឺ និងសំភារៈគ្រប់គ្រាន់

៩-មានបន្ទប់សម្រាប់អ្នកជំងឺសម្រាកត្រឹមត្រូវ

១០-មានបន្ទប់គ្រូពេទ្យ និងមានគ្រូពេទ្យប្រចាំការអចិន្ត្រៃយ៍

១១-មានទូរដាក់ឱសថសំភារៈ-បរិក្ខារពេទ្យ សម្រាប់ប្រើប្រាស់សមស្រប

១២-មានបន្ទប់រំងាប់មេរោគ ដែលបំពាក់ដោយឧបករណ៍រំងាប់មេរោគត្រឹមត្រូវ

១៣-មានប្រង់ការ រទេះរុញយ៉ាងតិច១ តាមជាន់នីមួយៗ

១៤-មានឧបករណ៍សម្លាប់មេរោគយ៉ាងតិច១

១៥-មានឃ្លាំងដាក់សំភារៈ

១៦-មានម៉ាស៊ីនភ្លើងបម្រុងសម្រាប់ប្រើប្រាស់ពេលដាច់ចរន្តម្តងៗ

១៧-មានបន្ទប់ទឹក និងបង្គន់អនាម័យស្អាត

១៨-មានប្រដាប់ពន្លត់អគ្គិភ័យ

១៩-មានឯកសារអ្នកជំងឺ (Dossier des malades)

២០-មានតារាងតម្លៃព្យាបាល

២១-ត្រូវផ្តល់របាយការណ៍អំពីសកម្មភាពព្យាបាលជំងឺឱ្យបានទៀងទាត់រៀងរាល់បីខែ (០៣ខែ) ម្តង ផ្ញើមកនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាលតាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត

២២-មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងធុងសំរាមសម្រាប់ដាក់សំណល់ទូទៅ និងសំណល់ឆ្លងរោគ និងបែងចែកទៅតាមប្រភេទសំណល់ ដែលបានកំណត់ដោយសេចក្តីណែនាំនៃក្រសួងសុខាភិបាល

២៣-មានប្រព័ន្ធទំនាក់ទំនងជាមួយមន្ទីរពេទ្យដែលមានឡសម្រាប់ដុតកាកសំណល់ផ្សេងៗ ។

26

ប្រការ ២៥.-

អាចបើកមន្ទីរសម្រាកព្យាបាលជំងឺផ្លូវចិត្តបានចំពោះតែ វេជ្ជបណ្ឌិត ដែលចូលនិវត្តន៍ ឬបោះបង់ការងាររដ្ឋ ឬផ្អាកការងាររដ្ឋដោយគ្មានបៀវត្ស ដែលបញ្ជាក់ដោយប្រធានស្ថាប័នសាមី។ ចំពោះអ្នកមិនបម្រើការងាររដ្ឋ ត្រូវមានបទពិសោធន៍វិជ្ជាជីវៈយ៉ាងតិច៥ឆ្នាំ បញ្ជាក់ដោយអង្គភាពសាមី និងបានចុះឈ្មោះជាសមាជិកគណៈគ្រូពេទ្យ និងត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

១-មានអគារសមរម្យជាមន្ទីរសម្រាកព្យាបាលជំងឺផ្លូវចិត្ត

២-មានស្លាកសញ្ញាមន្ទីរសម្រាកព្យាបាលជំងឺផ្លូវចិត្តត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល

៣-មានកន្លែងរង់ចាំ ២៤ម² យ៉ាងតិច និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៤-មានបន្ទប់ពិគ្រោះជំងឺ ដែលមានទំហំយ៉ាងតិច ១២ម²

៥-មានសៀវភៅសម្រាប់កត់ត្រាពីសកម្មភាពជំងឺប្រចាំថ្ងៃ

៦-ក្របខ័ណ្ឌបច្ចេកទេស និងអ្នកបម្រើការងារទូទៅគឺ

- សរុប ០.៧ បុគ្គលិក សម្រាប់គ្រែ ១ (គិតទាបបំផុត)
- បុគ្គលិកបច្ចេកទេសមានសញ្ញាប័ត្រលើសពី ៥០% នៃចំនួនបុគ្គលិកសរុប

៧-ត្រូវមានគ្រែយ៉ាងតិចបំផុត ១០គ្រែ យ៉ាងច្រើន ២០គ្រែ សម្រាប់អ្នកជំងឺសម្រាកព្យាបាល

៨-មានបន្ទប់ពិនិត្យជំងឺ និងសំភារៈគ្រប់គ្រាន់

៩-មានបន្ទប់សម្រាប់អ្នកជំងឺសម្រាកត្រឹមត្រូវ

១០-មានបន្ទប់គ្រូពេទ្យ និងមានគ្រូពេទ្យប្រចាំការអចិន្ត្រៃយ៍

១១-មានទូរដាក់ឱសថសំភារៈ-បរិក្ខារពេទ្យ សម្រាប់ប្រើប្រាស់សមស្រប

១២-មានបន្ទប់រំងាប់មេរោគ ដែលបំពាក់ដោយឧបករណ៍រំងាប់មេរោគត្រឹមត្រូវ

១៣-មានប្រដាប់ការ ទេះរុញយ៉ាងតិច១ តាមជាន់នីមួយៗ

១៤-មានឧបករណ៍សម្លាប់មេរោគយ៉ាងតិច១

១៥-មានឃ្លាំងដាក់សំភារៈ

១៦-មានម៉ាស៊ីនភ្លើងបម្រុងសម្រាប់ប្រើប្រាស់ពេលដាច់ចរន្តម្តងៗ

១៧-មានបន្ទប់ទឹក និងបង្គន់អនាម័យស្អាត

១៨-មានប្រដាប់ពន្លត់អគ្គីភ័យ

១៩-មានឯកសារអ្នកជំងឺ (Dossier des malades)

២០-មានតារាងតម្លៃព្យាបាល

២១-ត្រូវផ្តល់របាយការណ៍អំពីសកម្មភាពព្យាបាលជំងឺឱ្យបានទៀងទាត់រៀងរាល់បីខែ (០៣ខែ) ម្តង ផ្ញើមក

នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាលតាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត

២២-មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងថុងសំរាមសម្រាប់ដាក់សំណល់ទូទៅ និងសំណល់ឆ្លងរោគ និងបែងចែកទៅតាមប្រភេទសំណល់ ដែលបានកំណត់ដោយសេចក្តីណែនាំនៃក្រសួងសុខាភិបាល

២៣-មានប្រព័ន្ធទំនាក់ទំនងជាមួយមន្ទីរពេទ្យដែលមានឡសម្រាប់ដុតកាកសំណល់ផ្សេងៗ ។

ប្រការ ២៦.-

អាចបើកមន្ទីរព្យាបាលជំងឺកុមារបានចំពោះតែ វេជ្ជបណ្ឌិត ដែលចូលនិវត្តន៍ ឬបោះបង់ការងាររដ្ឋ ឬផ្អាកការងាររដ្ឋដោយគ្មានបៀវត្ស ដែលបញ្ជាក់ដោយប្រធានស្ថាប័នសាមី។ ចំពោះអ្នកមិនបម្រើការងាររដ្ឋ ត្រូវមានបទពិសោធន៍វិជ្ជាជីវៈយ៉ាងតិច៥ឆ្នាំ បញ្ជាក់ដោយអង្គភាពសាមី និងបានចុះឈ្មោះជាសមាជិកគណៈគ្រូពេទ្យ និងត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

១-មានអាគារសមរម្យជាមន្ទីរព្យាបាលជំងឺកុមារ

២-មានស្លាកសញ្ញាមន្ទីរព្យាបាលជំងឺកុមារត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល

៣-មានកន្លែងរង់ចាំ ១៦ម² យ៉ាងតិច និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៤-មានបន្ទប់ពិគ្រោះជំងឺ ដែលមានទំហំយ៉ាងតិច ១២ម²

៥-មានសៀវភៅសម្រាប់កត់ត្រាពីសកម្មភាពជំងឺប្រចាំថ្ងៃ

៦-ក្របខ័ណ្ឌបច្ចេកទេស និងអ្នកបម្រើការងារទូទៅគឺ

- សរុប ០.៧ បុគ្គលិក សម្រាប់គ្រែ ១ (កម្រិតទាបបំផុត)
- បុគ្គលិកបច្ចេកទេសមានសញ្ញាប័ត្រលើសពី ៩០% នៃចំនួនបុគ្គលិកសរុប

៧-ត្រូវមានគ្រែយ៉ាងតិចបំផុត ១០គ្រែ យ៉ាងច្រើន ២០គ្រែ សំរាប់អ្នកជំងឺសម្រាកព្យាបាល

៨-មានបន្ទប់សង្គ្រោះបន្ទាន់យ៉ាងតិច១

៩-មានបន្ទប់គ្រូពេទ្យ និងមានគ្រូពេទ្យប្រចាំការអចិន្ត្រៃយ៍

១០-មានទូរដាក់ឱសថសំភារៈបរិក្ខាពេទ្យ សម្រាប់ប្រើប្រាស់សមស្រប

១១-មានបន្ទប់រំងាប់មេរោគ ដែលបំពាក់ដោយឧបករណ៍រំងាប់មេរោគត្រឹមត្រូវ

១២-បន្ទប់ថតឆ្លុះ ត្រូវរៀបចំសមស្របតាមលក្ខណៈបច្ចេកទេស និងសេចក្តីណែនាំដែលមានចែងក្នុងស្តង់ដារសេវាឯកជនរបស់ក្រសួងសុខាភិបាល (បើមាន)

១៣-បន្ទប់ពិសោធន៍វេជ្ជសាស្ត្រ (បើមាន)

១៤-មានប្រង់ការ វេទេះរុញយ៉ាងតិច១ តាមជាន់នីមួយៗ

១៥-មានឧបករណ៍សម្លាប់មេរោគយ៉ាងតិច១

១៦-មានឃ្លាំងដាក់សំភារៈ

១៧-មានម៉ាស៊ីនភ្លើងបម្រុងសម្រាប់ប្រើប្រាស់ពេលដាច់ចរន្តម្តងៗ

១៨-មានបន្ទប់ទឹក និងបង្គន់អនាម័យស្អាត

១៩-មានប្រដាប់ពន្លត់អគ្គីភ័យ

២០-រថយន្តគិលានសង្គ្រោះ (បើមាន)

២១-បន្ទប់វះកាត់ ត្រូវរៀបចំសមស្របតាមលក្ខណៈបច្ចេកទេស និងសេចក្តីណែនាំដែលមានចែងក្នុងស្តង់ដារសេវាឯកជនរបស់ក្រសួងសុខាភិបាល (បើមាន) ។

២២-មានឯកសារអ្នកជំងឺ (Dossier des malades)

២៣-មានតារាងតម្លៃព្យាបាល

២៤-ត្រូវផ្តល់របាយការណ៍អំពីសកម្មភាពព្យាបាលជំងឺឱ្យបានទៀងទាត់រៀងរាល់បីខែ (០៣ខែ)ម្តង ផ្ញើមកនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាលតាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត

២៥-មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងថង់សំរាមសម្រាប់ដាក់សំណល់ទូទៅ និងសំណល់ឆ្លងរោគ និងបែងចែកទៅតាមប្រភេទសំណល់ ដែលបានកំណត់ដោយសេចក្តីណែនាំនៃក្រសួងសុខាភិបាល

២៦-មានប្រព័ន្ធទំនាក់ទំនងជាមួយមន្ទីរពេទ្យដែលមានឡសម្រាប់ដុតកាកសំណល់ផ្សេងៗ ។

## ប្រការ ២៧.-

អាចបើកមន្ទីរសម្ភព-រោគស្ត្រីបានចំពោះតែ វេជ្ជបណ្ឌិត ដែលចូលនិវត្តន៍ ឬបោះបង់ការងាររដ្ឋ ឬផ្អាកការងាររដ្ឋដោយគ្មានបៀវត្ស ដែលបញ្ជាក់ដោយប្រធានស្ថាប័នសាមី ។ ចំពោះអ្នកមិនបម្រើការងាររដ្ឋ ត្រូវមានបទពិសោធន៍វិជ្ជាជីវៈយ៉ាងតិច៥ឆ្នាំ បញ្ជាក់ដោយអង្គភាពសាមី និងបានចុះឈ្មោះជាសមាជិកគណៈគ្រូពេទ្យ និងត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

១-មានអាគារសមរម្យជាមន្ទីរសម្ភព

២-មានស្លាកសញ្ញាមន្ទីរសម្ភពត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល

៣-មានកន្លែងរង់ចាំ ១៦ម$^{២}$ យ៉ាងតិច និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៤-មានសៀវភៅសម្រាប់កត់ត្រាពីសកម្មភាពសម្ភព-រោគស្ត្រីប្រចាំថ្ងៃ

៥-មានបន្ទប់ពិគ្រោះទំហំយ៉ាងតិច ១២ម$^{២}$

៦-ត្រូវមានយ៉ាងតិចបំផុត ១០គ្រែ សម្រាប់ដាក់អ្នកសម្រាលកូន

៧-ក្របខ័ណ្ឌបុគ្គលិកត្រូវកំណត់ ០.៧ បុគ្គលិកសម្រាប់គ្រែ ១ (កម្រិតទាប) ក្នុងនោះត្រូវមាន

-គ្រូពេទ្យជំនាញខាងសម្ភពគិតតាមរបប ១២ នាក់ សម្រាប់គ្រែ ១០០

-ឆ្មបមានសញ្ញាប័ត្រ គិតតាមរបបយ៉ាងតិច ៣០នាក់ សម្រាប់គ្រែ ១០០

៨-មានបន្ទប់រំងាប់មេរោគ ដែលបំពាក់ដោយប្រដាប់រំងាប់មេរោគត្រឹមត្រូវ

៩-មានបន្ទប់គ្រូពេទ្យ និងមានគ្រូពេទ្យប្រចាំការអចិន្ត្រៃយ៍

១០-បន្ទប់អេកូក្រាហ្វី (បើមាន)

១១-មានបន្ទប់ពិនិត្យផ្ទៃពោះយ៉ាងតិច១កន្លែង និងមានសំភារៈប្រើប្រាស់គ្រប់គ្រាន់

១២-មានបន្ទប់សម្រាលកូនយ៉ាងតិច១កន្លែង និងមានសំភារៈប្រើប្រាស់គ្រប់គ្រាន់

១៣-មានបន្ទប់ក្រោយសម្រាលកូន ដោយមានដាក់គ្រែសមរម្យតាមទំហំបន្ទប់

១៤-ការរៀបចំត្រូវមានគ្រែសម្រាប់ម្តាយ១ និងគ្រែសម្រាប់ទារក១

១៥-បន្ទប់សង្គ្រោះបន្ទាន់យ៉ាងតិច១ មានទូរថ្នាំពេទ្យ បំពង់អុកស៊ីសែន និងសំភារៈចាំបាច់ផ្សេងៗសម្រាប់ការងារសង្គ្រោះបន្ទាន់

១៦-បន្ទប់វះកាត់ត្រូវរៀបចំសមស្របតាមលក្ខណៈបច្ចេកទេស និងសេចក្តីណែនាំដែលមានចែងក្នុងស្តង់ដារសេវាឯកជនរបស់ក្រសួងសុខាភិបាល (បើមាន)

១៧-មានសំភារៈឧបករណ៍ប្រើប្រាស់ខាងសម្ភពគ្រប់គ្រាន់សមស្រប

១៨-មានឃ្លាំងដាក់សំភារៈ ព្រមទាំងបំពង់ពន្លត់អគ្គិភ័យ

១៩-មានម៉ាស៊ីនភ្លើងបម្រុងសម្រាប់ប្រើប្រាស់ពេលដាច់ចរន្តម្តងៗ

២០-មានបន្ទប់ទឹក និងបង្គន់អនាម័យស្អាត

២១-មានប្រង់ការ រទេះរុញយ៉ាងតិច១ តាមជាន់នីមួយៗ

២២-រថយន្តគិលានសង្គ្រោះ (បើមាន)

២៣-មានឯកសារអ្នកជំងឺ (Dossier des malades)

២៤-មានតារាងតម្លៃព្យាបាល

២៥-ត្រូវផ្តល់របាយការណ៍អំពីសកម្មភាពព្យាបាលជំងឺឱ្យបានទៀងទាត់រៀងរាល់បីខែ (០៣ខែ)ម្តង ផ្ញើមកនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាលតាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត

២៦-មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងថង់សំរាមសម្រាប់ដាក់សំណល់ទូទៅ និងសំណល់ឆ្លងរោគ និងបែងចែកទៅតាមប្រភេទសំណល់ ដែលបានកំណត់ដោយសេចក្តីណែនាំនៃក្រសួងសុខាភិបាល

២៧-មានប្រព័ន្ធទំនាក់ទំនងជាមួយមន្ទីរពេទ្យដែលមានឡសម្រាប់ដុតកំទេចកាកសំណល់ប្រើប្រាស់។

ប្រការ ២៨.-

អាចបើកមន្ទីរសម្រាកព្យាបាលបានចំពោះតែ វេជ្ជបណ្ឌិត ដែលចូលនិវត្តន៍ ឬបោះបង់ការងាររដ្ឋ ឬផ្អាកការងាររដ្ឋដោយគ្មានបៀវត្ស ដែលបញ្ជាក់ដោយប្រធានស្ថាប័នសាមី។ ចំពោះអ្នកមិនបម្រើការងាររដ្ឋ ត្រូវមានបទពិសោធន៍វិជ្ជាជីវៈយ៉ាងតិច៥ឆ្នាំ បញ្ជាក់ដោយអង្គភាពសាមី និងបានចុះឈ្មោះជាសមាជិកគណៈគ្រូពេទ្យ និងត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

១-មានអាគារសមរម្យជាមន្ទីរសម្រាកព្យាបាល

២-មានស្លាកសញ្ញាមន្ទីរសម្រាកព្យាបាលត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខា



30

R

ភិបាល

៣-មានកន្លែងរង់ចាំ ១៦ម² យ៉ាងតិច និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៤-មានបន្ទប់ពិគ្រោះជំងឺ ដែលមានទំហំយ៉ាងតិច ១២ម²

៥-មានសៀវភៅសម្រាប់កត់ត្រាពីសកម្មភាពជំងឺប្រចាំថ្ងៃ

៦-ក្របខ័ណ្ឌបច្ចេកទេស និងអ្នកបម្រើការងារទូទៅគឺ

- សរុប ០.៧ បុគ្គលិក សម្រាប់គ្រែ ១ (កម្រិតទាបបំផុត)
- បុគ្គលិកបច្ចេកទេសមានសញ្ញាប័ត្រលើសពី ៥០% នៃចំនួនបុគ្គលិកសរុប

៧-ត្រូវមានគ្រែយ៉ាងតិចបំផុត ១០គ្រែ យ៉ាងច្រើន ២០គ្រែ សំរាប់អ្នកជំងឺសម្រាកព្យាបាល

៨-មានបន្ទប់សង្គ្រោះបន្ទាន់យ៉ាងតិច១

៩-មានបន្ទប់គ្រូពេទ្យ និងមានគ្រូពេទ្យប្រចាំការអចិន្ត្រៃយ៍

១០-មានទូរដាក់ឱសថសំភារៈ-បរិក្ខារពេទ្យ សម្រាប់ប្រើប្រាស់សមស្រប

១១-មានបន្ទប់រំងាប់មេរោគ ដែលបំពាក់ដោយឧបករណ៍រំងាប់មេរោគត្រឹមត្រូវ

១២-បន្ទប់ថតឆ្លុះ ត្រូវរៀបចំសមស្របតាមលក្ខណៈបច្ចេកទេស និងសេចក្តីណែនាំដែលមានចែងក្នុងស្តង់ដារសេវាឯកជនរបស់ក្រសួងសុខាភិបាល (បើមាន)

១៣-បន្ទប់ពិសោធន៍វេជ្ជសាស្ត្រ (បើមាន)

១៤-មានប្រង់ការ រទេះរុញយ៉ាងតិច១ តាមជាន់នីមួយៗ

១៥-មានឧបករណ៍សម្លាប់មេរោគយ៉ាងតិច១

១៦-មានឃ្លាំងដាក់សំភារៈ

១៧-មានម៉ាស៊ីនភ្លើងបម្រុងសម្រាប់ប្រើប្រាស់ពេលដាច់ចរន្តម្តងៗ

១៨-មានបន្ទប់ទឹក និងបង្គន់អនាម័យស្អាត

១៩-មានប្រដាប់ពន្លត់អគ្គីភ័យ

២០-រថយន្តគិលានសង្គ្រោះ (បើមាន)

២១-បន្ទប់វះកាត់ ត្រូវរៀបចំសមស្របតាមលក្ខណៈបច្ចេកទេស និងសេចក្តីណែនាំដែលមានចែងក្នុងស្តង់ដារសេវាឯកជនរបស់ក្រសួងសុខាភិបាល (បើមាន)

២២-មានឯកសារអ្នកជំងឺ (Dossier des malades)

២៣-មានតារាងតម្លៃព្យាបាល

២៤-ត្រូវផ្តល់របាយការណ៍អំពីសកម្មភាពព្យាបាលជំងឺឱ្យបានទៀងទាត់រៀងរាល់បីខែ (០៣ខែ)ម្តង ផ្ញើមកនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាលតាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត

២៥-មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងធុងសំរាមសម្រាប់ដាក់សំណល់ទូទៅ និងសំណល់ឆ្លងរោគ និងបែងចែកទៅតាមប្រភេទសំណល់ ដែលបានកំណត់ដោយសេចក្តីណែនាំនៃក្រសួងសុខាភិបាល



31

- 35

២៦-មានប្រព័ន្ធទំនាក់ទំនងជាមួយមន្ទីរពេទ្យដែលមានឡសម្រាប់ដុតកាកសំណល់ផ្សេងៗ។

ប្រការ ២៩.-

អាចបើកមន្ទីរពហុព្យាបាលបានចំពោះតែ វេជ្ជបណ្ឌិត ដែលចូលនិវត្តន៍ ឬបោះបង់ការងាររដ្ឋ ឬផ្អាកការងាររដ្ឋដោយគ្មានបៀវត្ស ដែលបញ្ជាក់ដោយប្រធានស្ថាប័នសាមី។ ចំពោះអ្នកមិនបម្រើការងាររដ្ឋ ត្រូវមានបទពិសោធន៍វិជ្ជាជីវៈយ៉ាងតិច៥ឆ្នាំ បញ្ជាក់ដោយអង្គភាពសាមី និងបានចុះឈ្មោះជាសមាជិកគណៈគ្រូពេទ្យ និងត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

១-មានអាគារយ៉ាងតិច២ល្វែង និង២ជាន់ឡើងទៅ ឬអាគារដោយឡែក សមស្របតាមផ្នែក និងតាមចំនួនគ្រែដែលមាន សមរម្យជាមន្ទីរពហុព្យាបាល

២-មានស្លាកសញ្ញាមន្ទីរពហុព្យាបាលត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្ដីណែនាំរបស់ក្រសួងសុខាភិបាល

៣-មានសេវាវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រច្រើនផ្នែក ដូចជាផ្នែកជំងឺទូទៅ ជំងឺកុមារ សម្ភព-រោគស្ត្រី ជំងឺវះកាត់ និងផ្នែកឯកទេសផ្សេងៗទៀត

៤-មានកន្លែងរង់ចាំ ២៤ម$^2$ យ៉ាងតិច និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៥-មានបន្ទប់ពិគ្រោះជំងឺ ដែលមានទំហំយ៉ាងតិច ១២ម$^2$

៦-មានសៀវភៅសម្រាប់កត់ត្រាពីសកម្មភាពជំងឺប្រចាំថ្ងៃ

៧-ក្របខ័ណ្ឌបច្ចេកទេស និងអ្នកបម្រើការងារទូទៅគឺ

- សរុប ០.៧ បុគ្គលិក សម្រាប់គ្រែ ១ (កម្រិតទាបបំផុត)
- បុគ្គលិកបច្ចេកទេសមានសញ្ញាប័ត្រលើសពី ៥០% នៃចំនួនបុគ្គលិកសរុប

៨-ត្រូវមានគ្រែយ៉ាងតិចបំផុត ២០គ្រែ យ៉ាងច្រើន ៤០គ្រែ

៩-មានបន្ទប់សង្គ្រោះបន្ទាន់យ៉ាងតិច១

១០-មានបន្ទប់ពិនិត្យជំងឺ និងសំភារៈគ្រប់គ្រាន់តាមផ្នែកនីមួយៗ

១១-មានបន្ទប់សម្រាប់អ្នកជំងឺសម្រាកតាមផ្នែកនីមួយៗគ្រប់គ្រាន់

១២-មានបន្ទប់គ្រូពេទ្យ និងមានគ្រូពេទ្យប្រចាំការអចិន្ត្រៃយ៍

១៣-មានទូរដាក់ឱសថ សំភារៈ-បរិក្ខារពេទ្យ សម្រាប់ប្រើប្រាស់សមស្រប

១៤-មានបន្ទប់រំងាប់មេរោគ ដែលបំពាក់ដោយឧបករណ៍រំងាប់មេរោគត្រឹមត្រូវ

១៥-បន្ទប់ថតឆ្លុះ ត្រូវរៀបចំសមស្របតាមលក្ខណៈបច្ចេកទេស និងសេចក្ដីណែនាំដែលមានចែងក្នុងស្តង់ដារសេវាឯកជនរបស់ក្រសួងសុខាភិបាល (បើមាន)

១៦-មានបន្ទប់ពិសោធន៍វេជ្ជសាស្ត្រ រៀបចំសមស្របតាមលក្ខណៈបច្ចេកទេស

១៧-មានប្រង់ការ ភេទះរុញយ៉ាងតិច១ តាមជាន់នីមួយៗ

១៨-មានឃ្លាំងដាក់សំភារៈ ព្រមទាំងបំពង់ពន្លត់អគ្គីភ័យ

១៩-មានម៉ាស៊ីនភ្លើងបម្រុងសម្រាប់ប្រើប្រាស់ពេលដាច់ចរន្តម្តងៗ

២០-មានបន្ទប់ទឹក និងបង្គន់អនាម័យស្អាត

២១-មានរថយន្តគិលានសង្គ្រោះ

២២-មានបន្ទប់វះកាត់ ត្រូវរៀបចំសមស្របតាមលក្ខណៈបច្ចេកទេស និងសេចក្តីណែនាំដែលមានចែងក្នុងស្តង់ដារសេវាឯកជនរបស់ក្រសួងសុខាភិបាល

២៣-មានឯកសារអ្នកជំងឺ (Dossier des malades)

២៤-មានតារាងតម្លៃព្យាបាល

២៥-ត្រូវផ្តល់របាយការណ៍អំពីសកម្មភាពព្យាបាលជំងឺឱ្យបានទៀងទាត់រៀងរាល់បីខែ (០៣ខែ) ម្តង ផ្ញើមកនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាលតាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត

២៦-មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងធុងសំរាមសម្រាប់ដាក់សំណល់ទូទៅ និងសំណល់ឆ្លងរោគ និងបែងចែកទៅតាមប្រភេទសំណល់ ដែលបានកំណត់ដោយសេចក្តីណែនាំនៃក្រសួងសុខាភិបាល

២៧-មានប្រព័ន្ធទំនាក់ទំនងជាមួយមន្ទីរពេទ្យដែលមានឡសម្រាប់ដុតកាកសំណល់ផ្សេងៗ។

ប្រការ ៣០.-

អាចបើកមន្ទីរពេទ្យឯកជនបានចំពោះតែ វេជ្ជបណ្ឌិត ដែលចូលនិវត្តន៍ ឬបោះបង់ការងាររដ្ឋ និងបានចុះឈ្មោះជាសមាជិកគណៈគ្រូពេទ្យ និងត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

១-មានអាគារដែលត្រូវសាងដោយឡែកតែឯង សមស្របតាមផ្នែក និងតាមចំនួនគ្រែដែលមាន និងសមជាមន្ទីរពេទ្យឯកជន

២-មានស្លាកសញ្ញាមន្ទីរពេទ្យឯកជនត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល

៣-មានសេវាវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រច្រើនផ្នែក ដូចជាផ្នែកជំងឺទូទៅ ជំងឺកុមារ សម្ភព-រោគស្ត្រី ជំងឺវះកាត់ និងផ្នែកឯកទេសផ្សេងៗទៀត

៤-មានកន្លែងរង់ចាំ ៤៨ម$^{២}$ យ៉ាងតិច និងមានកៅអី ឬសាឡុងសម្រាប់រង់ចាំ

៥-មានបន្ទប់ពិគ្រោះជំងឺ ដែលមានទំហំយ៉ាងតិច ១២ម$^{២}$

៦-មានសៀវភៅសម្រាប់កត់ត្រាជំងឺប្រចាំថ្ងៃ

៧-ក្របខ័ណ្ឌបច្ចេកទេស និងអ្នកបម្រើការងារទូទៅគឺ

- សរុប ០.៧ បុគ្គលិក សម្រាប់គ្រែ ១ (កម្រិតទាបបំផុត)
- បុគ្គលិកបច្ចេកទេសមានសញ្ញាប័ត្រលើសពី ៥០% នៃចំនួនបុគ្គលិកសរុប

៨-ត្រូវមានគ្រែយ៉ាងតិចបំផុតចំនួន៨០ សម្រាប់អ្នកជំងឺសម្រាកព្យាបាល



33

៩-មានបន្ទប់សង្គ្រោះបន្ទាន់យ៉ាងតិច១

១០-មានបន្ទប់ពិនិត្យជំងឺ និងសំភារៈគ្រប់គ្រាន់តាមផ្នែកនីមួយៗ

១១-មានបន្ទប់សម្រាប់អ្នកជំងឺសម្រាកតាមផ្នែកនីមួយៗគ្រប់គ្រាន់

១២-មានបន្ទប់គ្រូពេទ្យ និងមានគ្រូពេទ្យប្រចាំការអចិន្ត្រៃយ៍

១៣-មានបន្ទប់ឱសថស្ថានសម្រាប់បម្រើការក្នុងមន្ទីរពេទ្យ

១៤-បន្ទប់វះកាត់ ត្រូវរៀបចំសមស្របតាមលក្ខណៈបច្ចេកទេស និងសេចក្តីណែនាំដែលមានចែងក្នុងស្តង់ដារសេវាឯកជនរបស់ក្រសួងសុខាភិបាល

១៥-បន្ទប់ផតផ្ទះ ត្រូវរៀបចំសមស្របតាមលក្ខណៈបច្ចេកទេស និងសេចក្តីណែនាំដែលមានចែងក្នុងស្តង់ដារសេវាឯកជនរបស់ក្រសួងសុខាភិបាល (បើមាន)

១៦-មានបន្ទប់ពិសោធន៍វេជ្ជសាស្ត្រ រៀបចំសមស្របតាមលក្ខណៈបច្ចេកទេស

១៧-មានផ្នែករដ្ឋបាល ផ្នែកគណនេយ្យ និងផ្នែកបេឡា

១៨-មានផ្នែកគេហកិច្ច (អនាម័យ,បោកគក់,ដាំស្ល)

១៩-មានសំភារៈ-បរិក្ខារពេទ្យ សម្រាប់ប្រើប្រាស់សមស្រប

២០-មានបន្ទប់រំងាប់មេរោគ ដែលបំពាក់ដោយឧបករណ៍រំងាប់មេរោគត្រឹមត្រូវ

២១-មានប្រង់ការ១ រទេះរុញ១ តាមជាន់នីមួយៗ

២២-មានឧបករណ៍សម្លាប់មេរោគសមស្រប

២៣-មានឃ្លាំងដាក់សំភារៈ ព្រមទាំងបំពង់ពន្លត់អគ្គីភ័យ

២៤-មានម៉ាស៊ីនភ្លើងបម្រុងសម្រាប់ប្រើប្រាស់ពេលដាច់ចរន្តម្តងៗ

២៥-មានបន្ទប់ទឹក និងបង្គន់អនាម័យស្អាត

២៦-មានរថយន្តគិលានសង្គ្រោះ

២៧-មានឯកសារអ្នកជំងឺ (Dossier des malades)

២៨-មានតារាងតម្លៃព្យាបាល

២៩-ត្រូវផ្តល់របាយការណ៍អំពីសកម្មភាពព្យាបាលជំងឺឱ្យបានទៀងទាត់រៀងរាល់បីខែ (០៣ខែ)ម្តង ផ្ញើមកនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត

៣០-មានបន្ទប់ដាក់សាកសព

៣១-មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងធុងសំរាមសម្រាប់ដាក់សំណល់ទូទៅ និងសំណល់ឆ្លងរោគ និងបែងចែកទៅតាមប្រភេទសំណល់ ដែលបានកំណត់ដោយសេចក្តីណែនាំនៃក្រសួងសុខាភិបាល

៣២-មានប្រព័ន្ធទំនាក់ទំនងជាមួយមន្ទីរពេទ្យដែលមានឡសម្រាប់ដុតកាកសំណល់ផ្សេងៗ។

34



R

ប្រការ ៣១.-

អាចបើកមជ្ឈមណ្ឌលកែសម្ផស្សបានចំពោះតែ វេជ្ជបណ្ឌិត ដែលមិនបម្រើការងាររដ្ឋ និងបានចុះឈ្មោះជាសមាជិកគណៈគ្រូពេទ្យ និងត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

១-ត្រូវមានស្លាកសញ្ញាជាមជ្ឈមណ្ឌលកែសម្ផស្ស

២-មានកន្លែងរង់ចាំទំហំ ២៤ម$^2$

៣-មានសៀវភៅសម្រាប់កត់ត្រាពីសកម្មភាពកែសម្ផស្សប្រចាំថ្ងៃ

៤-មានកន្លែងពិគ្រោះទំហំយ៉ាងតិច ១៦ម$^2$

៥-គ្រែចម្ងាសសម្រាប់ពិនិត្យយ៉ាងច្រើន៤

៦-មជ្ឈមណ្ឌលកែសម្ផស្សមានសិទ្ធិ :

-កែច្រមុះ

-វះកាត់ត្របកភ្នែក

-ធ្វើថ្ពាល់ឱ្យខួច

-កែបបូរមាត់

-បំបាត់ស្លាកស្នាម

-សាក់ភ្នែក សាក់ចិញ្ចើម សាក់បបូរមាត់ លុបសាក់

-បណ្ដុះសក់

-កាត់ប្រជ្រុយ បំបាត់អាចម៍រុយ

-បំបាត់ភាពជ្រីវជ្រួញ បំបាត់ជ្រួញកន្ទុយភ្នែក បំបាត់ខ្មៅក្រោមភ្នែក

-កែសម្ផស្សដោយប្រើម៉ាស៊ីនឡាស៊ែរ .

៧-មានបន្ទប់សម្រាប់វះកាត់តូចតាចទំហំយ៉ាងតិច ១៦ម$^2$ និងបំពាក់ដោយគ្រែវះកាត់ ០១គ្រឿង .

៨-មានប្រអប់ប្រដាប់ប្រដាវះកាត់ និងសម្ភារៈសង្គ្រោះបន្ទាន់ត្រឹមត្រូវ

៩-មានចង្កៀងអ៊ុលត្រាវីយ៉ូឡេសម្រាប់រំងាប់មេរោគក្នុងបន្ទប់វះកាត់

១០-មានសម្ភារៈសម្លាប់មេរោគ ឬ Autoclave ឬ Etuve សម្រាប់រំងាប់មេរោគសម្ភារៈវះកាត់ មានសំឡីលុយស្បុង Antiseptique និងចេសដេរដែលមានគុណភាពមិនហួសកាលបរិច្ឆេទ .

១១-មានឱសថ និងបរិក្ខារពេទ្យប្រើប្រាស់សមស្រប

១២-មានបន្ទប់ទឹក និងបង្គន់អនាម័យត្រឹមត្រូវ

១៣-ត្រូវផ្ដល់របាយការណ៍អំពីសកម្មភាពព្យាបាលជំងឺឱ្យបានទៀងទាត់រៀងរាល់បីខែ (០៣ខែ)ម្ដង ផ្ញើមកនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត ។

ប្រការ ៣២.-

អាចបើកការិយាល័យតំណាង ឬការិយាល័យទំនាក់ទំនងសេវាសុខភាពបានចំពោះតែ វេជ្ជបណ្ឌិត ដែលបានចុះឈ្មោះជាសមាជិកគណៈគ្រូពេទ្យ និងត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

១-មានអាគារធម្មតា១ជាន់ ឬច្រើនជាន់ សមរម្យជាការិយាល័យទំនាក់ទំនងបញ្ជូនជំងឺ

២-មានស្លាកសញ្ញាត្រឹមត្រូវ ដែលបានកំណត់ដោយសេចក្ដីណែនាំរបស់ក្រសួងសុខាភិបាល

៣-មានកន្លែងរង់ចាំ ដែលមានទំហំយ៉ាងតូច ៨ម$^{2}$ និងមានកៅអី ឬសាឡុង សម្រាប់រង់ចាំ

៤-មានបន្ទប់ពិគ្រោះជំងឺ ដែលមានទំហំយ៉ាងតូច ១២ម$^{2}$

៥-មានគ្រែចំនួន១ ឬ២

៦-មានរថយន្តគិលានសង្គ្រោះ (បើមាន) ឬប្រព័ន្ធបញ្ជូនជំងឺសមស្រប

៧-មានសៀវភៅសម្រាប់កត់ត្រាពីសកម្មភាពនៃការបញ្ជូនជំងឺប្រចាំថ្ងៃ

៨-មានតារាងតម្លៃបញ្ជូនជំងឺ

៩-ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពបញ្ជូនជំងឺជាទៀងរាល់បីខែ (០៣ខែ) ម្ដង ផ្ញើមកនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត

១០-មិនអនុញ្ញាតដាក់តាំងលក់ឱសថក្នុងការិយាល័យតំណាងទំនាក់ទំនងបញ្ជូនជំងឺជាដាច់ខាត។

ប្រការ ៣៣.-

បន្ទប់ពិគ្រោះព្យាបាលជំងឺ បន្ទប់ពិគ្រោះព្យាបាលជំងឺមាត់-ធ្មេញ បន្ទប់ពិគ្រោះព្យាបាលជំងឺភ្នែក បន្ទប់ពិគ្រោះព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់ក បន្ទប់ពិគ្រោះព្យាបាលជំងឺសើស្បែក បន្ទប់ពិគ្រោះព្យាបាលជំងឺផ្លូវចិត្ត មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល មន្ទីរសម្ភព-រោគស្ត្រី មន្ទីរពិសោធន៍វេជ្ជសាស្ត្រ មន្ទីរព្យាបាលមាត់-ធ្មេញ មន្ទីរព្យាបាលជំងឺភ្នែក មន្ទីរព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់ក មន្ទីរព្យាបាលជំងឺសើស្បែក មន្ទីរព្យាបាលជំងឺផ្លូវចិត្ត មន្ទីរព្យាបាលជំងឺកុមារ ត្រូវមានវេជ្ជបញ្ជាត្រឹមត្រូវ មានសរសេរអាស័យដ្ឋានច្បាស់លាស់ មានហត្ថលេខាគ្រូពេទ្យព្យាបាលទទួលខុសត្រូវច្បាស់លាស់ និងសរសេរកម្រិត Dose ប្រើប្រាស់ថ្នាំឱ្យបានត្រឹមត្រូវ ព្រមទាំងកត់ត្រាឈ្មោះ ភេទ អាយុ អ្នកជំងឺ។

ប្រការ ៣៤.-

ការផ្ដល់លិខិតអនុញ្ញាតច្បាប់ជូនដល់ បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ បន្ទប់ថែទាំជំងឺ បន្ទប់ព្យាបាលដោយចលនា បន្ទប់ពិគ្រោះព្យាបាលជំងឺ បន្ទប់ពិគ្រោះព្យាបាលជំងឺមាត់-ធ្មេញ បន្ទប់ពិគ្រោះព្យាបាលជំងឺភ្នែក បន្ទប់ពិគ្រោះព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់ក បន្ទប់ពិគ្រោះព្យាបាលជំងឺសើស្បែក និងបន្ទប់ពិគ្រោះព្យាបាលជំងឺផ្លូវចិត្ត គឺផ្ដល់ជូនច្បាប់អនុញ្ញាតរយៈពេល ៣ឆ្នាំ ម្ដង និងមានផ្ដល់ជូនស្លាកសញ្ញាសំគាល់ Logo ស្របច្បាប់ដោយមានចុះលេខបញ្ជិកាសំគាល់ពីមន្ទីរសុខាភិបាលរាជធានី-ខេត្ត។

36



NK
R

ប្រការ ៣៥.-

ការផ្តល់លិខិតអនុញ្ញាតច្បាប់ជូនដល់ មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល មន្ទីរសម្ភព មន្ទីរពិសោធន៍វេជ្ជសាស្ត្រ មន្ទីរព្យាបាលមាត់-ធ្មេញ មន្ទីរព្យាបាល ជំងឺភ្នែក មន្ទីរព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់ក មន្ទីរព្យាបាលជំងឺសើស្បែក មន្ទីរព្យាបាលជំងឺផ្លូវចិត្ត មន្ទីរព្យាបាលជំងឺកុមារ គឺផ្តល់ជូនច្បាប់អនុញ្ញាតរយៈពេល ៥ឆ្នាំ ម្តង និងមានផ្តល់ជូនស្លាកសញ្ញាសំគាល់ Logo ស្របច្បាប់ដោយមានចុះលេខបញ្ជិកាសំគាល់ពីក្រសួងសុខាភិបាល។

ប្រការ ៣៦.-

ការផ្តល់លិខិតអនុញ្ញាតច្បាប់ជូនដល់មជ្ឈមណ្ឌលកែសម្ផស្ស ការិយាល័យតំណាង ឬការិយាល័យទំនាក់ទំនងសេវាសុខភាព គឺផ្តល់ច្បាប់អនុញ្ញាតរយៈពេល ២ឆ្នាំ ម្តង និងមានផ្តល់ជូនស្លាកសញ្ញាសំគាល់ Logo ស្របច្បាប់ដោយមានចុះលេខបញ្ជិកាសំគាល់ពីក្រសួងសុខាភិបាល។

ប្រការ ៣៧.-

គ្រប់សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន ទាំងអស់ដែលទទួលបានច្បាប់អនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈហើយ ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពព្យាបាលជំងឺរៀងរាល់ត្រីមាសមកក្រសួងសុខាភិបាល (នាយកដ្ឋានមន្ទីរពេទ្យ) តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្តឱ្យបានទៀតទាត់។ ករណីមិនគោរពតាមប្រការនេះ ក្រសួងសុខាភិបាលនឹងផ្អាកសកម្មភាពសេវា និងដកយកលិខិតអនុញ្ញាតវិញ ព្រមទាំងមិនអនុញ្ញាតច្បាប់នៅពេលសុំបន្តសុពលភាព។

ប្រការ ៣៨.-

ការបើកមន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល មន្ទីរសម្ភព មន្ទីរពិសោធន៍វេជ្ជសាស្ត្រ មន្ទីរព្យាបាលមាត់-ធ្មេញ មន្ទីរព្យាបាលជំងឺភ្នែក មន្ទីរព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់ក មន្ទីរព្យាបាលជំងឺសើស្បែក មជ្ឈមណ្ឌលកែសម្ផស្ស មន្ទីរព្យាបាលជំងឺផ្លូវចិត្ត និងមន្ទីរព្យាបាលជំងឺកុមារ ណាដែលមានបញ្ចូលជនបរទេសមកធ្វើការជាមួយ ជនបរទេសទាំងនោះ ត្រូវគោរពតាមអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីបែបបទ និងលក្ខខ័ណ្ឌបច្ចេកទេសក្នុងការអនុញ្ញាតឱ្យជនបរទេសប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជននៅព្រះរាជាណាចក្រកម្ពុជា។

ប្រការ ៣៩.-

សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន ដែលបានទទួលការអនុញ្ញាតឱ្យបើកពីមុនមក ត្រូវមកបំពេញបន្ថែមនូវទម្រង់បែបបទ និងរៀបចំទីតាំងឱ្យមានលក្ខណៈសមស្របតាមប្រកាសនេះឱ្យបានត្រឹមត្រូវតាមបទបញ្ញត្តិនៃច្បាប់។

ប្រការ ៤០.-

បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ បន្ទប់ថែទាំជំងឺ បន្ទប់ព្យាបាលដោយចលនា បន្ទប់ពិគ្រោះព្យាបាលជំងឺ បន្ទប់ពិគ្រោះព្យាបាលជំងឺមាត់-ធ្មេញ បន្ទប់ពិគ្រោះព្យាបាលជំងឺភ្នែក បន្ទប់ពិគ្រោះព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់ក បន្ទប់ពិគ្រោះព្យាបាលជំងឺ សើស្បែក បន្ទប់ពិគ្រោះព្យាបាលជំងឺផ្លូវចិត្ត មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល មន្ទីរសម្ភព-រោគស្ត្រី មន្ទីរពិសោធន៍វេជ្ជសាស្ត្រ មន្ទីរព្យាបាលមាត់-ធ្មេញ មន្ទីរព្យាបាលជំងឺភ្នែក មន្ទីរព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់ក មន្ទីរព្យាបាលជំងឺសើស្បែក មន្ទីរព្យាបាលជំងឺផ្លូវចិត្ត មន្ទីរព្យាបាលជំងឺកុមារ មជ្ឈមណ្ឌលកែសម្ផស្ស និងការិយាល័យតំណាង ឬការិយាល័យទំនាក់ទំនងសេវាសុខភាព ត្រូវបង្កលក្ខណៈគ្រប់បែបយ៉ាងដល់ការត្រួតពិនិត្យរបស់គណៈកម្មការ ឬភ្នាក់ងារត្រួតពិនិត្យក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាលរាជធានី-ខេត្ត ។

ប្រការ ៤១.-

ខ្លឹមសារប្រកាសលេខ ០២១ អបស/មព ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៣ របស់ក្រសួងសុខាភិបាល ព្រមទាំងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនិងប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ ៤២.-

អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល នាយកដ្ឋានមន្ទីរពេទ្យ និងមន្ទីរសុខាភិបាលរាជធានី-ខេត្ត មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៤៣.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

កន្លែងទទួល :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា-រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងយុត្តិធម៌
- ក្រសួងមហាផ្ទៃ
- សាលារាជធានី-ខេត្ត
- អគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ ក្រសួងសុខាភិបាល
- នាយកដ្ឋានមន្ទីរពេទ្យ (ដើម្បីអនុវត្ត)
- គណៈវិជ្ជាជីវៈថ្នាក់ជាតិ និងរាជធានី-ខេត្ត
- មន្ទីរសុខាភិបាលរាជធានី-ខេត្ត (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

ម៉ម_ប៊ុនហេង